អង្គការសហប្រជាជាតិ

A/HRC/21/35

មហាសន្និបាត

ចែកចាយ : ទូទៅ
២០ កញ្ញា ២០១២

អត្ថបទដើម ៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីម្ភៃមួយ**
របៀបវារៈចំណុច ២ និងចំណុច ១០
**របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យ ឧត្តមស្នងការ និងអគ្គលេខាធិការ**

**ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

# តួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយឧបត្ថម្ភដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស

**របាយការណ៍របស់អគ្គលេខាធិការ** *

* ការបញ្ជូនយឺតពេល

GE. 12 - 16852

មាតិការឿង

*កថាខ័ណ្ឌ* *ទំព័រ*

I. សេចក្តីផ្តើម ........................................................................................................ ៣- ៤

II. កំណែទម្រង់ពន្ធនាគារ ........................................................................................ ៤- ៨

III. សេរីភាពជាមូលដ្ឋាននិងសង្គមស៊ីវិល ............................................................................. ៨-១១

IV. សិទ្ធិដីធ្លី និងលំនៅដ្ឋាន ........................................................................................ ១១- ១៥

V. នីតិរដ្ឋ ..............................................................................................................១៥- ២០

VI. ព័ត៌មានសាធារណៈ និងការអប់រំសិទ្ធិមនុស្ស ..........................................................២០- ២១

VII. ការធ្វើរបាយការណ៍ និងតាមមើលការអនុវត្ត ...........................................................២១- ២២

VIII. ការងារបុគ្គលិក ......................................................................................................២២- ២២

## I. សេចក្តីផ្តើម

១. របាយការណ៍នេះ ត្រូវបានដាក់ជូនស្របតាមសេចក្តីសំរេចចិត្តលេខ១៨/២៥ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលបរិយាយអំពីសកម្មភាពការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យOHCHR) ប្រចាំកម្ពុជា ក្នុងអំឡុងពេលចាប់ពីខែកក្កដា ឆ្នាំ២០១១ ដល់ ខែមិថុនា ឆ្នាំ២០១២ ។

២. វត្តមានរបស់ការិយាល័យOHCHR ប្រចាំកម្ពុជា ត្រូវបានគណៈកម្មការសិទ្ធិមនុស្ស អ.ស.ប ប្រគល់អាណត្តិឲ្យក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួន លេខ១៩៩៣/៦ បានបន្តជួយឧបត្ថម្ភដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកស្ទួយ និងការគោរពសិទ្ធិមនុស្ស។ នៅក្នុងអំឡុងពេលស្ថិតក្រោមការពិនិត្យឡើងវិញនេះ កម្មវិធីសហប្រតិបត្តិការរបស់ការិយាល័យOHCHR ជាមួយរដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍ បានបន្តផ្តោតសំខាន់លើវិស័យធំៗចំនួនប្រាំគឺ៖ ការគាំទ្រកំណែទម្រង់ពន្ធនាគារ ការការពារសេរីភាពជាមូលដ្ឋាន និងការអភិវឌ្ឍន៍សង្គមស៊ីវិល ការការពារសិទ្ធិដីធ្លី និងលំនៅដ្ឋាន ការគាំទ្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការលើកកំពស់កេរ្តិ៍ដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)។

៣. អនុលោមតាមអាណត្តិរបស់ខ្លួន ការិយាល័យOHCHR បានបន្តធ្វើការងារជាមួយដៃគូរដ្ឋាភិបាលក្នុងស្មារតីនៃការសន្ទនាប្រកបដោយន័យស្ថាបនា និងការគោរពគ្នាទៅវិញទៅមក។ ដូចដែលសកម្មភាពបានបង្ហាញស្រាប់នៅក្នុងរបាយការណ៍នេះ ការិយាល័យOHCHR បានសឲ្យឃើញថា ជាប្រភពមួយដ៏រឹងមាំនៃជំនាញការបច្ចេកទេសលើវិស័យសិទ្ធិមនុស្ស ដែលកម្ពុជានៅតែបន្តប្រឈមនឹងការលំបាកបំផុតមួយចំនួន។ ភស្តុតាងជាក់ច្បាស់ថែមទៀត បានបង្ហាញតាមរយៈការសម្រេចរបស់រដ្ឋាភិបាល បន្តរយៈពេលពីរឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១២ នូវអនុស្សរណៈយោគយល់គ្នា(MoU) របស់ខ្លួន ដែលគ្រប់គ្រងលើការផ្តល់ជំនួយឧបត្ថម្ភផ្នែកបច្ចេកទេសដោយការិយាល័យOHCHR។ ទន្ទឹមនឹងនេះ ការិយាល័យOHCHR បានគាំទ្រដល់កិច្ចពិភាក្សាទ្វេរភាគីជាមួយសមភាគីរដ្ឋាភិបាល នៅពេលមានការលើកឡើងអំពីបញ្ហាលំបាកស្មុគស្មាញខាងសិទ្ធិមនុស្ស ក្នុងករណីរំលោភសិទ្ធិមនុស្សមួយៗដាច់ដោយឡែក ហើយម្តងម្កាលការិយាល័យOHCHR បានលើកអំពីកង្វល់ផ្សេងៗជាសាធារណៈ ស្របតាមអាណត្តិសកលរបស់ឧត្តមស្នងការសិទ្ធិមនុស្ស។

៤. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ បានកត់សំគាល់ឃើញមានហេតុផលមួយចំនួន។ មួយគឺថា កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងការិយាល័យOHCHR បានល្អប្រសើរនៅក្នុងវិស័យមួយចំនួន ចាប់តាំងពីពេលធ្វើរបាយការណ៍លើកមុន។ វឌ្ឍនភាពនេះ ត្រូវបានការិយាល័យOHCHR ទទួលស្វាគមន៍។ កិច្ចសហប្រតិបត្តិការភាគច្រើន ដែលបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះ ផ្តោតលើការភ្ជាប់ការយល់ដឹងពីសិទ្ធិមនុស្ស និងចន្លោះប្រហោងសមត្ថភាពក្នុងរដ្ឋាភិបាល។ ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការនេះ ដូចសព្វដង ត្រូវបានធ្វើការវាយតំលៃ អំពីផលប៉ះពាល់របស់វា ទៅលើការទទួលបានសិទ្ធិមនុស្ស ដោយមនុស្សគ្រប់រូប នៅកម្ពុជា។

៥. ការិយាល័យOHCHR បានបង្កើនការងាររបស់ខ្លួន លើករណីមួយៗដាច់ដោយឡែក នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ដោយបានធ្វើទស្សនកិច្ចជាង ១៥០ លើក ដើម្បីស៊ើបអង្កេតករណីដែលមានអះអាងពីការរំលោភសិទ្ធិមនុស្សនៅគ្រប់ខេត្ត-ក្រុង ទូទាំងប្រទេស។ ការងារនេះ បានបញ្ជាក់ពីនិន្នាការគួរឲ្យព្រួយបារម្ភមួយចំនួន រួមមាន៖

(ក) ភាពស្រួចស្រាវនៃទំនាស់ច្រើនលើសលុប ពាក់ព័ន្ធនឹងបញ្ហាដីធ្លី ហើយអំពើហឹង្សាមានការកើនឡើងទៅលើភាគីសហគមន៍ ដែលការពារសិទ្ធិដីធ្លីរបស់ខ្លួន

(ខ) និទណ្ឌភាពនៅតែបន្តមានចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងមានការកាត់ទោសឆាប់រហ័សតាមទំនើងចិត្ត លើអ្នកការពារសិទ្ធិមនុស្ស

(គ) កំណើនមួយគួរឲ្យកត់សំគាល់ ក្នុងការប្រើប្រាស់គ្រាប់កាំភ្លើងពិត ដោយកំលាំងសន្តិសុខប្រឆាំងនឹងប្រជាពលរដ្ឋដែលទាមទារសិទ្ធិរបស់ខ្លួន (នៅអំឡុងពេលប្រាំខែដំបូង ក្នុងឆ្នាំ២០១២ ការិយាល័យOHCHR បានស៊ើបអង្កេតករណីបង្ករបួសស្នាមចំនួនប្រាំករណី ដែលមានការប្រើប្រាស់គ្រាប់កាំភ្លើងពិត ក្នុងនោះមានពីរករណីបានបណ្ដាលឲ្យមនុស្សស្លាប់ ៖ លោក ឈុត វុទ្ធី ជាសកម្មជនបរិស្ថាន នៅខេត្តកោះកុង និងកុមារីម្នាក់ ឈ្មោះ ហេង ចន្ថា អាយុ ១៤ ឆ្នាំ នៅខេត្តក្រចេះ)។

៦. កម្ពុជាបានធ្វើជាប្រធានសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១២ ហើយក្នុងតួនាទីនេះ កម្ពុជាមានទំនួលខុសត្រូវដឹកនាំការតាក់តែងសេចក្ដីប្រកាសស្ដីពីសិទ្ធិមនុស្សអាស៊ាន។ ប្រការនេះ បានធ្វើឲ្យមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ចាប់អារម្មណ៍ខ្លាំងឡើងថែមទៀត លើបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា ជាពិសេស នៅក្នុងកិច្ចប្រជុំធំៗរបស់អាស៊ាន ដែលបានរៀបចំធ្វើនៅកម្ពុជា។ កម្ពុជាបានចូលដល់ដំណាក់កាលនៃការបោះឆ្នោតមួយសំរាប់រយៈពេលពីរឆ្នាំ គឺការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ២០១២ និងការបោះឆ្នោតជាតិ ដែលគ្រោងធ្វើនៅពាក់កណ្ដាលឆ្នាំ២០១៣ នេះ។ ទោះជាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ជាទូទៅ មិនមានអំពើហិង្សាក្ដី ក៏មានការអះអាងគួរឲ្យជឿទុកចិត្តបានអំពីភាពមិនប្រក្រតីផងដែរ។ ការិយាល័យOHCHR ផ្ដោតលើបរិបទទូលំទូលាយជាងនេះ ក្នុងការបោះឆ្នោត រាប់ទាំង សេរីភាពក្នុងការបញ្ចេញមតិ និងលទ្ធភាពទទួលបានព័ត៌មាន។ កង្វល់ដូចនេះ ត្រូវបានបរិយាយនៅក្នុងរបាយការណ៍នេះ។

## II. កំណែទម្រង់ពន្ធនាគារ

៧. ការិយាល័យOHCHR បានបន្តអនុវត្តកម្មវិធីរបស់ខ្លួន គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់ពន្ធនាគារ។ វឌ្ឍនភាពសំខាន់មួយ គឺការប្រកាសឲ្យប្រើច្បាប់ថ្មីស្ដីពីពន្ធនាគារ ក្នុងខែធ្នូ ឆ្នាំ២០១១។ ការិយាល័យOHCHR បានធ្វើការវិភាគច្បាប់លើសេចក្ដីព្រាងជាបន្តបន្ទាប់នៃច្បាប់នេះ ដោយផ្អែកលើបទដ្ឋានសិទ្ធិមនុស្ស និងបានផ្ដល់អត្ថបទវិភាគនេះជូនអាជ្ញាធរពាក់ព័ន្ធ។ ក្នុងខែតុលា ឆ្នាំ២០១១ ការិយាល័យOHCHR បានផ្ដល់មតិមួយចំនួនផងដែរ ដល់សមាជិកសភា ខណៈពេលដែលសេចក្ដីព្រាងច្បាប់នេះកំពុងដំណើរការពិភាក្សាអនុម័តនៅក្នុងរដ្ឋសភា។ ច្បាប់ស្ដីពីពន្ធនាគារ ដែលបានប្រកាសឲ្យប្រើនេះ គឺជាច្បាប់ដ៏សំខាន់មួយ សំរាប់ការធ្វើកំណែទម្រង់ និងការពង្រឹងប្រព័ន្ធពន្ធនាគារ ហើយវាបានបង្កប់ក្នុងទិសដៅគោលនយោបាយច្បាប់ដែលរាជរដ្ឋាភិបាល បានប្រកាន់យកឈានទៅធ្វើកំណែទម្រង់ពន្ធនាគារ នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ការិយាល័យOHCHR បានផ្ដល់ការជួយឧបត្ថម្ភផ្នែកបច្ចេកទេសស្រដៀងគ្នានេះដល់ក្រសួងមហាផ្ទៃ លើបទដ្ឋានគតិយុត្តក្រោមច្បាប់ ដែលនឹងត្រូវពិនិត្យឡើងវិញ ក្រោយពីការប្រកាសឲ្យប្រើច្បាប់ថ្មីនេះ (មានជាអាទិ៍ ព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសំរាប់មន្ត្រីពន្ធនាគារ ព្រះរាជក្រឹត្យស្ដីពីការបន្ធូរបន្ថយទោស និងលើកលែងទោស និងប្រកាសស្ដីពីបទដ្ឋានប្លង់អប្បបរមាសំរាប់ការសាងសង់ពន្ធនាគារ)។ តបតាមការស្នើសុំរបស់អគ្គនាយកដ្ឋានពន្ធនាគារ ការិយាល័យOHCHR បានរៀបចំផងដែរ នូវបទបង្ហាញបទដ្ឋានមួយ មានគោលដៅលើកកំពស់ការយល់ដឹងអំពីបញ្ញត្តិច្បាប់ថ្មីនេះ និងបញ្ញត្តិមួយចំនួនដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ដល់មន្ត្រីគ្រប់គ្រងពន្ធនាគារ។

៨. ដោយមានការពិគ្រោះយោបល់យ៉ាងជិតដល់ជាមួយអង្គការពលកម្មអន្តរជាតិ(ILO) ការិយាល័យOHCHR បានធ្វើបច្ចុប្បន្នភាពផងដែរ នូវឯកសារសារតាស្ដីពីពលកម្មក្នុងពន្ធនាគារនៅកម្ពុជា។ ឯកសារនេះ បង្ហាញពីក្របខ័ណ្ឌ

ច្បាប់អន្តរជាតិពាក់ព័ន្ធ កំណត់ពីចំណុចចន្លោះប្រហោងនៅក្នុងក្របខ័ណ្ឌច្បាប់ជាតិ និងផ្តល់អនុសាសន៍អំពីវិធីសាស្ត្រផ្សេងៗដែលអាចធ្វើបាន។ ឯកសារនេះ ត្រូវបានចែកចាយទូទៅ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួងស្តីពីពលកម្មក្នុងពន្ធនាគារ ដែលបានសហការរៀបចំដោយការិយាល័យOHCHR អង្គការពលកម្មអន្តរជាតិ(ILO) ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងខែមីនា ឆ្នាំ២០១២។ បន្ទាប់ពីការពិគ្រោះយោបល់រួចមក ក្រសួងទាំងបីនេះ បានចេញសេចក្តីណែនាំអន្តរក្រសួងមួយ ហាមប្រាមការនាំចេញផលិតផលទាំងឡាយដែលបានផលិតនៅក្នុងពន្ធនាគារ។ ឧប្បត្តិហេតុក្នុងអតីតកាលពាក់ព័ន្ធនឹងផលិតផលក្នុងពន្ធនាគារ សំរាប់ការនាំចេញទៅក្រៅប្រទេស បានលើកឡើងជាកង្វល់ថា ដៃគូរពាណិជ្ជកម្មមួយចំនួនរបស់កម្ពុជា អាចនឹងហាមប្រាមការនាំចូលផលិតផលមួយផ្នែក ឬទាំងស្រុង ដែលបានផលិតនៅក្នុងពន្ធនាគារ។ ការិយាល័យOHCHR អង្គការពលកម្មអន្តរជាតិ(ILO) និងរាជរដ្ឋាភិបាល មានកង្វល់ថា សិទ្ធិការងាររបស់កម្មករ-កម្មការិនីកម្ពុជារាប់ពាន់នាក់ ជាពិសេសកម្មករ-កម្មការិនីទាំងឡាយដែលបំរើការក្នុងវិស័យកាត់ដេរ អាចប្រឈមនឹងហានិភ័យ។ អាស្រ័យហេតុនេះ ការហាមប្រាមដាច់ខាតនេះ គឺជាជំហានមួយដ៏សំខាន់ ហើយការិយាល័យOHCHR បន្តកិច្ចសន្ទនាជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីស្វែងរកកាលានុវត្តភាព ដើម្បីឲ្យជនជាប់ឃុំមានឱកាសធ្វើការងារ និងចាប់យកមុខជំនាញថ្មី។

៩. រយៈពេលពេញមួយឆ្នាំ ការិយាល័យOHCHR បានបន្តការគាំទ្ររបស់ខ្លួនដល់ការបង្កើតវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីពន្ធនាគារ តាមរយៈកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពទូទៅ។ ការិយាល័យOHCHR បានបន្តកិច្ចសន្ទនារបស់ខ្លួន ជាមួយក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីបង្កើតបរិយាកាសអំណោយផលមួយស្វែងរកជាពិសេស ដើម្បីធ្វើឲ្យប្រាកដថា ព្រះរាជក្រឹត្យ (ដែលនឹងត្រូវពិនិត្យឡើងវិញនៅថ្ងៃខាងមុខ) ស្តីពីលក្ខន្តិកៈដោយឡែកសំរាប់មន្ត្រីពន្ធនាគារ បញ្ចូលបទបញ្ញត្តិមួយចំនួនចែងច្បាស់អំពីវគ្គបណ្តុះបណ្តាលមន្ត្រីពន្ធនាគារទាក់ទងដល់ការជ្រើសរើស ការតែងតាំង និងការតម្លើងឋានន្តរស័ក្តិ។ តាមរយៈភាពជាដៃគូរជាមួយវិទ្យាស្ថានបណ្តុះបណ្តាល VBNK ការិយាល័យOHCHR បានចាប់ផ្តើមអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលរយៈពេលមួយឆ្នាំ សំរាប់ក្រុមគ្រូបណ្តុះបណ្តាលរួមគ្នាមួយ មកពីអគ្គនាយកដ្ឋានពន្ធនាគារ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារនៃរាជបណ្ឌិត្យសភានគរបាលកម្ពុជា។ សិក្ខាសាលាសំរាប់វគ្គបណ្តុះបណ្តាលគ្រូបង្គោលដែលមានរយៈពេលមួយសប្តាហ៍ចំនួនបីសិក្ខាសាលា ត្រូវបានរៀបចំឡើង រវាងខែតុលា ឆ្នាំ២០១១ និងខែឧសភា ឆ្នាំ២០១២ វគ្គបណ្តុះបណ្តាលជាក្រុម ឬជាបុគ្គល ឆ្លាស់វេនគ្នា ដែលបានរៀបចំឡើងសំរាប់សិក្ខាកាមទាំងអស់ ដើម្បីបង្កើនការយល់ដឹងពីសិក្ខាសាលានេះ។ កម្មវិធីនេះ បានផ្តោតលើជំនាញ និងវិធីសាស្ត្របណ្តុះបណ្តាល រាប់ទាំង របៀបធ្វើផែនការបណ្តុះបណ្តាល ការរៀបចំឯកសារមេរៀន ការសម្របសម្រួល និងការផ្តល់វគ្គបណ្តុះបណ្តាល។ តាមរយៈការវាយតំលៃវគ្គ សិក្ខាកាមមានទស្សនៈវិជ្ជមានខ្លាំង ចំពោះការប្រឹងប្រែងរៀនសូត្រ នៅទូទាំងដំណើរការនៃវគ្គបណ្តុះបណ្តាលនេះទាំងមូល។

១០. ស្របគ្នានេះដែរ ការិយាល័យOHCHR បានបន្តការងាររបស់ខ្លួន គាំទ្រដល់ការរៀបចំបង្កើតខ្លឹមសារកម្មវិធីមេរៀនសំរាប់វគ្គបណ្តុះបណ្តាលចាំបាច់ដល់មន្ត្រីពន្ធនាគារមុនពេលចូលបម្រើការងារ។ ការិយាល័យOHCHR ធានាផ្តល់ជំនាញឯកទេសសំរាប់ការរៀបចំម៉ូឌុលបច្ចេកទេសមួយចំនួន រួមបញ្ចូលទាំង "សុខភាពក្នុងពន្ធនាគារ" (ជាអាទិ៍ អំពីមេរោគហ៊ីវ/អេដស៍ និងជម្ងឺរបេង) ក្នុងភាពជាដៃគូរជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) ហើយដែលទាក់ទងនឹងសុខភាពផ្លូវចិត្ត ការគ្រប់គ្រងស្ត្រេស (ជម្ងឺថប់អារម្មណ៍) និងការដោះស្រាយជម្លោះក្នុងពន្ធនាគារ។ នៅក្នុងខែមិថុនា ឆ្នាំ២០១២ ការិយាល័យOHCHR បានរៀបចំផងដែរ នូវវគ្គបណ្តុះបណ្តាលរយៈពេលមួយសប្តាហ៍បន្ថែមដល់ក្រុមគ្រូបង្គោល ដោយអ្នកជំនាញការអន្តរជាតិមួយរូប ដែលមានជំនាញខាងរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីពន្ធនាគារ ដែលបានចុះកិច្ចសន្យាជាមួយការិយាល័យOHCHR។ វគ្គបណ្តុះបណ្តាលនេះ មានគោលដៅជួយដល់ក្រុមគ្រូបង្គោល ក្នុងការកំណត់ច្បាស់អំពីគោលបំណងនៃវគ្គបណ្តុះ

បណ្តាល ដោយផ្អែកលើសេចក្តីត្រូវការ ដែលកំណត់ក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារកម្ពុជា និងបង្កើតខ្លឹមសារបណ្តុះបណ្តាលដោយខ្លួនឯងសំរាប់មន្ត្រីពន្ធនាគារ ស្របតាមក្របខ័ណ្ឌជាតិ។ ជាផ្នែកមួយនៃការរៀបចំវគ្គបណ្តុះបណ្តាល និងឯកសារយោង ការិយាល័យOHCHR បានធ្វើការពិនិត្យឡើងវិញនូវឯកសារជាភាសាខ្មែរ ចំពោះបញ្ញត្តិជាបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ សំរាប់គ្រប់គ្រងជនជាប់ឃុំ ហើយបានពិនិត្យចប់សព្វគ្រប់សំរាប់ធ្វើការចែកជូននូវសំណៅបកប្រែជាភាសាខ្មែរនៃបញ្ញត្តិរបស់អង្គការសហប្រជាជាតិសំរាប់គ្រប់គ្រងជនជាប់ឃុំជាស្ត្រី និងវិធានការមិនឃុំខ្លួន សំរាប់ជនល្មើសជាស្ត្រី។

១១. ការិយាល័យOHCHR បានបន្តការប្រាស្រ័យទាក់ទងល្អជាមួយអាជ្ញាធរពន្ធនាគារ ការចុះទៅមើលពន្ធនាគារជាទៀងទាត់ និងមានលទ្ធភាពធ្វើការសម្ភាសន៍ជាសម្ងាត់ជាមួយជនជាប់ឃុំ។ ការិយាល័យOHCHR នៅតែជាអង្គការមួយក្នុងចំណោមអង្គការចំនួនពីរនៅក្នុងប្រទេស ដែលមានសិទ្ធិចុះទៅធ្វើទស្សនកិច្ចនៅតាមពន្ធនាគារ ដោយគ្មានការរាំង ដើម្បីពិនិត្យមើលលក្ខខណ្ឌទូទៅ និងប្រព្រឹត្តកម្ម ឬធ្វើការតាមដានលើសំណូមពរបុគ្គល ពាក្យបណ្តឹង ឬការចោទប្រកាន់អំពីការរំលោភបំពាន ឬប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន។ ការចុះត្រួតពិនិត្យ និងឃ្លាំមើលរបស់ការិយាល័យ OHCHR នាំឲ្យមានសកម្មភាពតាមដានមួយចំនួន ដើម្បីជួយលើកបញ្ហាដែលបានសំគាល់ឃើញទាំងនេះ មកពិភាក្សារកដំណោះស្រាយ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅក្នុងពន្ធនាគារ។

១២. ការិយាល័យOHCHR បានបន្តធ្វើជម្រឿនជនជាប់ឃុំដែលជាប់បណ្តឹងឧទ្ធរណ៍ នៅទូទាំងប្រទេស ដែលការនេះបានជួយដល់អាជ្ញាធរពន្ធនាគារឲ្យបន្តធ្វើតាំងពីដើមឆ្នាំ២០១១មក។ ទិន្នន័យដែលប្រមូលបាន ត្រូវបានយកមកធ្វើការវិភាគ និងចែកជូនដល់អាជ្ញាធរពាក់ព័ន្ធ។ ជាពិសេស តារាងត្រូវបានរៀបចំ បែងចែកករណីបណ្តឹងទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួន មានជាអាទិ៍៖ ជនជាប់ឃុំជាប់បណ្តឹងឧទ្ធរណ៍រយៈពេលលើសពី៥ ឆ្នាំ ៧ ឆ្នាំ និងលើសពី១០ ឆ្នាំ ជានីតិជន និង ជាអនីតិជន ជនជាប់ឃុំដែលបានជាប់លើសកាលកំណត់របស់ឧទ្ធរណ៍ គឺក្រុមនេះបន្តជាប់ឃុំលើសពីថ្ងៃកំណត់ទោសចុងក្រោយរបស់សាលាដំបូង (រាប់បញ្ចូលទាំង ជនជាប់ឃុំដែលសាលាដំបូងបានសម្រេចលើកលែងចោទប្រកាន់ផងដែរ)។ ដូច្នេះ ជនជាប់ឃុំបែបនេះ អាចត្រូវបានគេផ្តល់អទិភាពសំរាប់ជំនួយផ្នែកច្បាប់ និងសវនាការនៅសាលាឧទ្ធរណ៍។

១៣. ផ្នែកមួយដែលផ្តោតជាពិសេសក្នុងកំឡុងឆ្នាំនេះដែរ គឺការរៀបចំបង្ការ និងជំនួយគ្រោះមហន្តរាយនៅកំរិតពន្ធនាគារ។ ជាធម្មតា ដូចប្រទេសមួយចំនួននៅក្នុងតំបន់ ប្រទេសកម្ពុជាបានទទួលឥទ្ធិពលដោយទឹកជំនន់យ៉ាងធ្ងន់ធ្ងរកាលពីចុងឆ្នាំ២០១១ និងពន្ធនាគារមិនត្រូវបានលើកលែងដែរ ជាពិសេសជាងគេនោះ គឺពន្ធនាគារខេត្តសៀមរាបតែម្តង។ ការិយាល័យOHCHR បានឆ្លើយតបយ៉ាងឆាប់រហ័ស និងផ្តល់ជំនួយដល់ពន្ធនាគារដែលរងគ្រោះ ដើម្បីជួយដល់ពន្ធនាគារទាំងនោះ ក្នុងការធានាការឃុំខ្លួនដោយសុវត្ថិភាព ទន្ទឹមនឹងការការពារសិទ្ធិជនជាប់ឃុំ រួមទាំងសិទ្ធិទទួលបានទឹកស្អាត និងអនាម័យ និងសិទ្ធិប្រព្រឹត្តកម្មមនុស្សធម៌ជាទូទៅ (រួមបញ្ចូលទាំងការចេញយកខ្យល់អាកាសខាងក្រៅផងដែរ)។ ការគាំទ្រការងារសង្គ្រោះបន្ទាន់ ដែលការិយាល័យOHCHR បានធ្វើ រួមមានការផ្តល់ខ្សាច់ និងបាវខ្សាច់សំរាប់ធ្វើជារបាំងទប់ទឹក ម៉ាស៊ីនបូមទឹក និងប្រេងម៉ាស៊ូត ដើម្បីបូមទឹកចេញ ថ្នាំទឹកសុវត្ថិភាពសំរាប់ទឹកស្អាត និងសម្ភារៈអនាម័យសំរាប់សំអាតនិងថ្នាំពេទ្យ ដើម្បីបន្ថយផលប៉ះពាល់លើផ្នែកសុខភាពរបស់មន្ត្រីពន្ធនាគារ ព្រមទាំងជនជាប់ឃុំ។ បន្ថែមលើការផ្តល់ជំនួយសង្គ្រោះបន្ទាន់ ការិយាល័យOHCHR បានធ្វើការជាមួយប្រធានពន្ធនាគារ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីវាយតំលៃហានិភ័យ និងកំណត់ដំណោះស្រាយសំរាប់ការពារ និងបន្ធូរបន្ថយទឹកជំនន់។ ដោយសារតែជនជាប់ឃុំមិនអាចប្តូរទីកន្លែង ឬជម្លៀសដោយងាយស្រួលបាន ក្នុងកំឡុងពេលមានគ្រោះមហន្តរាយ កិច្ច

ខិតខំប្រឹងប្រែងច្រើន គួរត្រូវបានអនុវត្តជាមុន ដើម្បីការពារ ឬបន្ថយហានិភ័យពីដំបូង។ ការិយាល័យOHCHR ក្រសួងមហាផ្ទៃ និងគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំបង្ការគ្រោះទឹកជំនន់ និងអគ្គីភ័យក្នុងពន្ធនាគារ ក្នុងខែកក្កដា ឆ្នាំ២០១២។

១៤. ការិយាល័យOHCHR បន្តលើកកំពស់សិទ្ធិសុខភាពរបស់ជនជាប់ឃុំ។ នេះរួមបញ្ចូលទាំងការតស៊ូមតិជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីបញ្ចូលបញ្ញត្តិលើកលែងទោសដោយមូលហេតុសុខភាព នៅក្នុងព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស នៅថ្ងៃអនាគត ក្នុងករណីដែលជនជាប់ឃុំមានជម្ងឺដែលអាចនឹងបាត់បង់ជីវិត ឬពុំនោះទេ សំរាប់ជនជាប់ឃុំទាំងឡាយណាដែលសុខភាពគាត់មានសភាពធ្ងន់ធ្ងរខ្លាំង ដែលមិនសមស្របសំរាប់ការឃុំខ្លួន ហើយដែលនឹងមិនបង្កការគំរាមកំហែងដល់សង្គម ក្រោយពេលដែលគាត់ត្រូវបានដោះលែងចេញពីពន្ធនាគារ។ ការិយាល័យOHCHR បានបន្តគាំទ្រ និងតស៊ូមតិ ឲ្យមានការជួសជុលកែលំអរបន្ទប់ច្រើនទៀត នៅក្នុងមន្ទីរពេទ្យ ដើម្បីឲ្យនៅពេលដែលជនជាប់ឃុំត្រូវបានបញ្ជូនទៅសំរាកព្យាបាលនៅមន្ទីរពេទ្យ គាត់ត្រូវបានបញ្ជូនតាមរបៀបមួយដែលធានាសុវត្ថិភាពឃុំខ្លួន និងដោយគោរពសេចក្តីថ្លៃថ្នូររបស់គាត់។ ក្នុងឆ្នាំ២០១២ ការិយាល័យOHCHR បាន និងកំពុងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុផងដែរ ដល់អាជ្ញាធរខេត្តបន្ទាយមានជ័យ សំរាប់បន្ទប់សំរាកព្យាបាលដូចគ្នានេះនៅក្នុងមន្ទីរពេទ្យបង្អែកខេត្ត។

១៥. ក្នុងវិស័យអប់រំ ការិយាល័យOHCHR បានសហការ និងបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឈ្មោះ Soutien à L'Initiative Privée pour l'Aide à LaReconstruction des Pays du Sud-Est Asiatique (SIPAR) ដើម្បីបង្កើតបណ្ណាល័យនៅក្នុងពន្ធនាគារចំនួនបួន នេះជាគម្រោងមួយដែល SIPAR នឹងបន្តពង្រីកថែមទៀត ដល់ពន្ធនាគារទាំង ២៥ នៅទូទាំងប្រទេស ក្នុងរយៈពេល ៣ ឆ្នាំបន្ទាប់ ។

១៦. ការិយាល័យOHCHR បន្តយកចិត្តទុកដាក់ខ្លាំងលើការជួយឧបត្ថម្ភដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សក្នុងវិស័យទឹកស្អាត និងអនាម័យ។ នៅក្នុងបរិបទនេះ ការងារចម្បងមួយ ក្នុងឆ្នាំ២០១១-២០១២ គឺការគាំទ្រដល់ការបញ្ចប់ការងារជួសជុលកែលំអរបណ្តាញចែកចាយទឹក ក្នុងពន្ធនាគារដែលមានចំនួនជនជាប់ឃុំច្រើនជាងគេ មណ្ឌលអប់រំកែប្រែទីមួយ(CC1) ដែលតាំងនៅជាយរាជធានីភ្នំពេញ។ ការវាយតំលៃលើកដំបូង បានបង្ហាញថា បរិមាណទឹកមានមិនគ្រប់គ្រាន់ សំរាប់ផ្គត់ផ្គង់ឲ្យជនជាប់ឃុំ ដោយសារតែមានការលិចធ្លាយ តាមបណ្តាញចែកចាយទឹក និងបញ្ហាទឹកមានកករខ្លាំង ដែលមិនអាចឲ្យមនុស្សប្រើប្រាស់បានសមរម្យ។ ដោយមានការឧបត្ថម្ភគាំទ្រពីការិយាល័យOHCHR ជនជាប់ឃុំរាប់ពាន់នាក់ក្នុងមណ្ឌលអប់រំកែប្រែទីមួយ បច្ចុប្បន្ននេះ មានទឹកស្អាតប្រើប្រាស់ទូទាំងពន្ធនាគារសំរាប់ការប្រើប្រាស់ជាទូទៅ។ នៅក្នុងពន្ធនាគារប្រាំផ្សេងទៀត ការឧបត្ថម្ភគាំទ្រដល់ការផ្គត់ផ្គង់ទឹកបានធ្វើជាបន្តបន្ទាប់ ចាប់ពីការចាប់តំលើងប្រព័ន្ធប្រមូលទឹកភ្លៀង រហូតដល់ការផ្តល់ធុងទឹកសំរាប់ផ្ទុកទឹកបន្ថែម ការសាងសង់អាងទឹកខ្ពស់ និងការចែកចាយធុងចម្រោះទឹកស្អាត ដើម្បីធានាភាពស្អាតនៃទឹកផឹក (ក្នុងពន្ធនាគារខេត្តកំពង់ធំ ឧត្តរមានជ័យ ក្រចេះ សៀមរាប និងមណ្ឌលអប់រំកែប្រែទី៤)។

១៧. ការិយាល័យOHCHR បន្តធ្វើការវាយតំលៃ និងធ្វើឲ្យប្រសើរឡើងដល់ទិដ្ឋភាពផ្សេងទៀតក្នុងលក្ខខណ្ឌពន្ធនាគារ រួមមាន ការធ្វើឲ្យមានខ្យល់អាកាសចេញចូល និងពន្លឺគ្រប់គ្រាន់ ព្រមទាំងការប្រើប្រាស់ឲ្យបានកាន់តែប្រសើរឡើងថែមទៀតនូវកន្លែងទំនេរក្នុងបន្ទប់ឃុំ (មាននៅមណ្ឌលអប់រំកែប្រែទីមួយ ទីពីរ ស្ទឹងត្រែង និងពន្ធនាគារខេត្តក្រចេះ) ការចេញយកខ្យល់អាកាសខាងក្រៅអគារ និងចូលរួមសកម្មភាពផ្សេងដូចជា កសិកម្ម ឬការដាំដុះ (មាន

នៅកំពង់ស្ពឺ និងស្ទឹងត្រែង) និងការរក្សាបាននូវចំណងទាក់ទងមួយសាច់ញាតិគ្រួសារ តាមរយៈការជួសជុលឡើងវិញនូវអគារជួបសួរសុខទុក្ខពីគ្រួសារ នៅក្នុងពន្ធនាគារខេត្តក្រចេះ។

**III. សេរីភាពជាមូលដ្ឋាន និងសង្គមស៊ីវិល**

១៨. កម្មវិធីសេរីភាពជាមូលដ្ឋាន និងសង្គមស៊ីវិល មានគោលដៅជួយពង្រឹងសមត្ថភាពបុគ្គល និងអង្គការទាំងឡាយ ក្នុងការអនុវត្តសេរីភាពជាមូលដ្ឋានខាងការបញ្ចេញមតិយោបល់ សិទ្ធិសមាគម និងសិទ្ធិជួបប្រជុំរបស់ពួកគេ។ កម្មវិធីនេះ ធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិល បណ្តាភ្នាក់ងារអង្គការសហប្រជាជាតិ ស្ថានទូត និងតួអង្គអភិវឌ្ឍន៍ផ្សេងៗ ដើម្បីបង្កើត និងឃ្លាំមើលការអនុវត្តច្បាប់ និងគោលនយោបាយដែលទាក់ទងផ្ទាល់ទៅនឹងការអនុវត្តសេរីភាពទាំងនេះ រាប់ទាំងការតាមឃ្លាំមើលករណីមួយៗពេលដែលកើតមាន។ កម្មវិធីនេះ ផ្តោតទៅលើការកសាងសមត្ថភាពផងដែរ ដល់រដ្ឋាភិបាល និងសង្គមស៊ីវិល។ សង្គមស៊ីវិលដ៏សកម្មរបស់កម្ពុជា នៅតែជាកេរ្តិ៍តំណែលវិជ្ជមាន ដែលកើតចេញពីដំណើរការសន្តិភាពនៃប្រទេសកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាល(NGOs) បន្តដើរតួនាទីដ៏សំខាន់ ក្នុងការតស៊ូមតិ និងជួយជំរុញឲ្យមានការផ្លាស់ប្តូរនៅក្នុងសង្គម ជួយផ្តល់សេវាសង្គមផ្សេងៗនៅទូទាំងប្រទេស ព្រមទាំងជួយឃ្លាំមើលសកម្មភាពរបស់ស្ថាប័ននីតិប្រតិបត្តិ និងវិស័យឯកជន។

១៩. វគ្គបណ្តុះបណ្តាលដល់អ្នកការពារសិទ្ធិមនុស្ស បានបន្តបង្កើតបានជាផ្នែកមួយដ៏សំខាន់នៃការងាររបស់ការិយាល័យOHCHR នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ កម្មវិធីនេះ ផ្តល់វគ្គបណ្តុះបណ្តាល ដើម្បីបង្កើនសមត្ថភាពដល់អ្នកការពារសិទ្ធិមនុស្សនៅទូទាំងប្រទេស ក្នុងការតាមឃ្លាំមើល ការរៀបចំចងក្រងឯកសារ និងការធ្វើរបាយការណ៍អំពីការរំលោភសិទ្ធិមនុស្ស។ នៅក្នុងខែកក្កដា សីហា តុលា ឆ្នាំ២០១១ និងនៅក្នុងខែមិថុនា ឆ្នាំ២០១២ ការិយាល័យOHCHR បានរៀបចំវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ ស្តីពីការឃ្លាំមើល និងការរៀបចំចងក្រងឯកសារពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សសំរាប់សកម្មជនសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន។ វគ្គបណ្តុះបណ្តាលនេះ បានរៀបចំធ្វើនៅខេត្តកំពត បាត់ដំបង កំពង់ចាម និងខេត្តព្រះសីហនុ ហើយមានការចូលរួមពីសកម្មជនមកពីគ្រប់បណ្តាខេត្តទាំងអស់។ នៅក្នុងខែធ្នូ ឆ្នាំ២០១១ វគ្គបណ្តុះបណ្តាលមួយទៀត បានរៀបចំធ្វើផងដែរ នៅខេត្តកំពង់ចាមសំរាប់សកម្មជនសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល(NGOs) ដោយផ្តោតលើយន្តការសិទ្ធិមនុស្សអន្តរជាតិ។ នៅក្នុងខែមីនា ឆ្នាំ ២០១២ ការិយាល័យOHCHR បានរៀបចំវគ្គបណ្តុះបណ្តាលមួយ ស្តីពីការឃ្លាំមើល និងការរៀបចំចងក្រងឯកសារពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស នៅរាជធានីភ្នំពេញ សំរាប់សកម្មជនដែលធ្វើការលើវិស័យការពារសិទ្ធិជនពិការ។ នៅទីបំផុត នៅក្នុងខែមិថុនា ឆ្នាំ ២០១២ ការិយាល័យOHCHR សហការជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(CHRC) សមាគមសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា(ADHOC) និងក្រុមមេធាវីសំរិទ្ធ បានរៀបចំវគ្គបណ្តុះបណ្តាលមួយសំរាប់សមាជិកមកពីគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(CHRC) ព្រឹទ្ធសភា និងរដ្ឋសភា ព្រមទាំងមន្ត្រីរាជការមកពីអង្គភាពប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងភេរវកម្មរបស់រាជរដ្ឋាភិបាល។ សរុបទាំងអស់ មានសកម្មជនសិទ្ធិមនុស្សចំនួនជាង ១៧០ នាក់ និង មន្ត្រីរដ្ឋាភិបាលចំនួន ១៨ នាក់ បានទទួលប្រយោជន៍ពីវគ្គបណ្តុះបណ្តាលទាំងនោះ។

២០. ការលើកកំពស់ការយល់ដឹងពីសិទ្ធិប្រជាពលរដ្ឋ ក្នុងការជួបប្រជុំ និងការបញ្ចេញមតិដោយសន្តិវិធី ក៏ជាផ្នែកមួយដ៏សំខាន់នៃកម្មវិធីបណ្តុះបណ្តាលរបស់ការិយាល័យOHCHR ផងដែរ។ ដោយសហការជាមួយវិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចិម(EWMI) ការិយាល័យOHCHR បានបើកវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី និងគោលការណ៍ណែនាំអនុវត្តច្បាប់នេះ ដល់អ្នកការពារសិទ្ធិមនុស្ស មកពីបណ្តាសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងសហជីពនានា។ វគ្គបណ្តុះបណ្តាលនេះ បានធ្វើនៅរាជធានីភ្នំពេញ ក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០១១ នៅ

ខេត្តព្រះសីហនុ ក្នុងខែធ្នូ ឆ្នាំ២០១១ នៅខេត្តសៀមរាប ក្នុងខែមេសា ឆ្នាំ២០១២ និងនៅខេត្តក្រចេះ ក្នុងខែមិថុនា ឆ្នាំ២០១២។ លើសពីនេះទៀត ដោយសហការជាមួយសភាពការងារកម្ពុជា(CLC) ការិយាល័យOHCHR បានរៀបចំសិក្ខាសាលាមួយ រយៈពេលមួយថ្ងៃ នៅខេត្តព្រះសីហនុ ក្នុងខែធ្នូ ឆ្នាំ២០១១ ដោយមានសកម្មជនសិទ្ធិមនុស្ស និងសកម្មជនសហជីពជាង ៤០០ នាក់ ចូលរួម។

២១. ការិយាល័យOHCHR បានបន្តសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីលើកកំពស់ការយល់ដឹងដល់មន្ត្រីរាជការស៊ីវិល អំពីរបៀបអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ក្នុងលក្ខណៈមួយស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា។ កិច្ចសហប្រតិបត្តិការនេះ រាប់ទាំងការធ្វើបញ្ចប់សៀវភៅមេរៀនរួមគ្នាមួយ សំរាប់ "បណ្តុះបណ្តាលគ្រូបង្គោល" ដែលនឹងត្រូវប្រើប្រាស់សំរាប់បណ្តុះបណ្តាលដល់មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍លើកក្រោយ។ ការិយាល័យOHCHR បានសំគាល់ឃើញកំរិតយល់ដឹងស្រពិចស្រពិល ក្នុងចំណោមមន្ត្រីរាជការស៊ីវិល ដែលបំរើការនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ពាក់ព័ន្ធនឹងការអនុវត្តច្បាប់នេះ។ ភាពស្រពិចស្រពិលនេះ បានបណ្តាលឲ្យសកម្មភាពមួយចំនួន ដែលសហគមន៍បានគ្រោងរៀបចំប្រារព្ធទិវាសិទ្ធិមនុស្សក្នុងឆ្នាំ២០១១ (ហើយដែលការិយាល័យOHCHR បានតាមឃ្លាំមើល) ត្រូវបានបង្អាក់ ឬត្រូវបានលុបចោល។ អ្វីដែលជាកង្វល់បន្ថែមទៀតនោះគឺថា ក្នុងករណីមួយចំនួន អាជ្ញាធរបន្តយកសេចក្តីណែនាំ ដែលក្រសួងមហាផ្ទៃបានចេញមុនច្បាប់នេះចូលជាធរមាន មកប្រើប្រាស់ ក្នុងការរារាំងប្រជាពលរដ្ឋមិនឲ្យជួបប្រជុំគ្នាដោយសន្តិវិធី ដើម្បីពិភាក្សាបញ្ហានយោបាយដ៏ចម្រូងចម្រះ។ ការិយាល័យOHCHR សង្ឃឹមថា ការផ្សព្វផ្សាយបន្ថែមអំពីច្បាប់ និងគោលការណ៍ណែនាំអនុវត្តច្បាប់នេះ ជាមួយ ក្រសួងមហាផ្ទៃ និងវិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម(EWMI) ព្រមទាំង ការតស៊ូមតិដោយការិយាល័យOHCHR នឹងជួយជម្រះចេញនូវភាពស្រពិចស្រពិលជុំវិញការអនុវត្តច្បាប់នេះ។

២២. ការការពារ និងការលើកស្ទួយសិទ្ធិទទួលបានព័ត៌មាន និងការធានាដល់សេរីភាពខាងសារព័ត៌មាន នៅតែបន្តជាកង្វល់នៅកម្ពុជា។ ទោះជាមានវឌ្ឍនភាពពីដំបូង ក្នុងការជួយដល់រដ្ឋាភិបាល ដើម្បីបង្កើតច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិក្តី ក៏ការិយាល័យOHCHR បានចូលរួមមិនបានច្រើនណាស់ណាទេ នៅក្នុងដំណើរការរៀបចំតាក់តែងច្បាប់នេះ តាំងពីឆ្នាំ២០០៧ មក។ នៅពេលធ្វើរបាយការណ៍នេះ សមាជិកមួយរូបនៃគណៈបក្សប្រឆាំងបានរៀបចំសេចក្តីព្រាងច្បាប់មួយ ដែលច្បាប់នេះរដ្ឋសភាកំពុងពិនិត្យ។ ក្នុងពេលជាមួយគ្នានេះដែរ មានអ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួន មកពីក្នុង និងក្រៅរដ្ឋាភិបាល បន្តទទួលស្គាល់ថា សារព័ត៌មានមួយឯករាជ្យគឺជាសសរទ្រូងមួយដ៏សំខាន់នៃលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ការិយាល័យOHCHR បានធ្វើការជាមួយអ្នកពាក់ព័ន្ធទាំងនេះមួយចំនួន (រាប់ទាំងអ្នកសារព័ត៌មាន និងសមាគមអ្នកសារព័ត៌មាន ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល(NGOs) និងអ្នកផ្តល់ជំនួយ) ក្នុងការរិះរកវិធីសាស្ត្រផ្សេងៗ ដើម្បីពង្រឹងក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន និងការពារវិជ្ជាជីវៈរបស់ពួកគេ។ ការងារនេះ រាប់ទាំង ការចូលរួមក្នុងគំនិតផ្តួចផ្តើមបណ្តុះបណ្តាលវិទ្យុសហគមន៍ ដែលរៀបចំឡើងដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ(អង្គការUNESCO) និងមជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM) នៅខេត្តមណ្ឌលគិរី កាលពីខែតុលា ឆ្នាំ២០១១។ មួយវិញទៀត ក្នុងភាពជាដៃគូជាមួយអង្គការUNESCO និងដោយសហការជាមួយ សមាគមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសារព័ត៌មានជាតិ ចំនួន ៧ ការិយាល័យOHCHR បានរៀបចំប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោក នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ ដោយផ្តោតសំខាន់លើការលើកកំពស់វិជ្ជាជីវៈសារព័ត៌ដែលមានការទទួលខុសត្រូវនៅកម្ពុជា។ ចូលរួមក្នុងពិធីនេះ មានតំណាងមកពីរដ្ឋាភិបាល និងភ្នាក់ងារអង្គការសហប្រជាជាតិ និងអ្នកសារព័ត៌មាន បុគ្គលិកនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ព្រមទាំង និស្សិតសាកលវិទ្យាល័យផ្សេងៗជាង ១៣០ នាក់។

២៣. ទោះជាមានការខិតខំប្រឹងប្រែងរួមខាងលើ ដើម្បីចូលរួមលើកកំពស់ការយល់ដឹង និងការបណ្តុះបណ្តាលជំនាញក្តី ក៏លទ្ធភាពរបស់បុគ្គលនិងក្រុមប្រជាពលរដ្ឋ ក្នុងការអនុវត្តសេរីភាពជាមូលដ្ឋានដោយសន្តិវិធី នៅតែជាបញ្ហាប្រឈម។ អ្វីដែលជាកង្វល់ខ្លាំងនោះគឺ និន្នាការទូទៅឈានទៅការប្រើប្រាស់កម្លាំងមានការកើនឡើង និងមិនសមាមាត្រ រាប់ទាំង ការប្រើប្រាស់គ្រាប់កាំភ្លើងពិតប្រឆាំងនឹងអ្នកតវ៉ា ដោយអាជ្ញាធររដ្ឋ និងសន្តិសុខឯកជន ជាមធ្យោបាយបង្ក្រាបអ្នកតវ៉ា។ ករណីអំពើហឹង្សាទាំងនេះ ភាគច្រើនបំផុតបានប្រើដោយគ្មានមូលហេតុត្រឹមត្រូវ ហើយជាពិសេសទាក់ទងនឹងបញ្ហាទំនាស់ដីធ្លី។ លើសពីនេះទៀត ការិយាល័យOHCHR បានសំគាល់ឃើញ យ៉ាងហោចណាស់ក៏មួយករណីដែរ ដែលក្នុងនោះ មានការតវ៉ាមួយទាក់ទងនឹងវិវាទការងារ បានឈានដល់ការប្រើប្រាស់កម្លាំងមិនសមាមាត្រ រាប់ទាំងការបាញ់ប្រហារទៅលើអ្នកតវ៉ាបីនាក់ ផងដែរ[1]។

២៤. កំណើននៃការប្រើប្រាស់កម្លាំង តបតនឹងការអនុវត្តសេរីភាពទាំងនេះ បានអមដោយនិន្នាការគួរឲ្យព្រួយបារម្ភក្នុងការប្រើប្រាស់ក្រមព្រហ្មទណ្ឌ។ ប្រជាជនកម្ពុជា បន្តប្រឈមនឹងហានិភ័យនៃការចោទប្រកាន់ពីបទញុះញង់ពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន។ ការប្រើប្រាស់ទូទៅនៃការចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌចាស់នោះ បច្ចុប្បន្ននេះ ត្រូវបានដាក់ជំនួសនៅក្នុងក្រមព្រហ្មទណ្ឌថ្មីដោយការចោទប្រកាន់បុគ្គលពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋវិញ។ ម្យ៉ាងវិញទៀត ក្នុងករណីជាច្រើន តុលាការទំនងជាមិនបានអនុវត្ត តាមកាតព្វកិច្ចដែលមានចែងក្នុងមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR)ឡើយ ដោយសំអាងពីអញ្ញត្រកម្មចំពោះការអនុវត្តសិទ្ធិនេះ ហើយការផ្តន្ទាទោសដែលតុលាការបានធ្វើទៀតសោត ក៏ទំនងជាមិនមានលក្ខណៈចាំបាច់ និងមិនសមាមាត្រផងដែរ នៅពេលធ្វើការពិចារណាលើអង្គហេតុនៃករណីទាំងនេះ។

២៥. ភាពមិនប្រក្រតីជាច្រើនទៀត ត្រូវបានសំគាល់ឃើញមានផងដែរ ទាក់ទងនឹងបណ្តឹងដទៃទៀត នៅក្នុងតុលាការពាក់ព័ន្ធនឹងការអនុវត្តសេរីភាពជាមូលដ្ឋាន ដែលក្នុងនោះ មានករណីថ្មីៗបំផុតមួយចំនួន បានបណ្តាលឲ្យមានការកាត់ទោសសកម្មជនដីធ្លី ១៥ នាក់ ឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំប្រាំមួយខែ បន្ទាប់ពីបានដំណើរការនីតិវិធីរយៈពេលកន្លះថ្ងៃមក ហើយដែលក្នុងអំឡុងពេលនោះ មិនមានសាក្សីដោះបន្ទុកណាមួយ ត្រូវបានតុលាការកោះហៅមកផ្តល់សក្ខីកម្មឡើយ។ សាលាឧទ្ធរណ៍ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ បានតំកល់សាលក្រមសាលាដំបូង ប៉ុន្តែបានសម្រេចព្យួរទោសនោះទាំងអស់ ដោយឲ្យពួកគាត់ជាប់ឃុំក្នុងម្នាក់ៗរយៈពេល ១ ខែ ៣ ថ្ងៃ ជារយៈពេលដែលពួកគាត់បានជាប់ពន្ធនាគាររួចហើយ។

២៦. ការិយាល័យOHCHR បានសំគាល់ឃើញថា កម្ពុជាបានទទួលយកអនុសាសន៍មួយចំនួន ដែលបានធ្វើនៅក្នុងអំឡុងពេលនៃការពិនិត្យរបាយការណ៍សកលតាមកាលកំណត់(UPR)របស់ខ្លួន ដែលអំពាវនាវឲ្យធ្វើការពិនិត្យឡើងវិញលើក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងគោលដៅធានាឲ្យការអនុវត្តក្រមនេះ ស្របតាមការកំរិតកំណត់ដែលអនុញ្ញាតចំពោះសេរីភាពក្នុងការបញ្ចេញមតិ ដូចមានចែងក្នុងកតិកាសញ្ញា ICCPR។

២៧. ក្រៅពីការឃ្លាំមើលបាតុកម្ម និងតុលាការ ការិយាល័យOHCHR បានបន្តឃ្លាំមើលមជ្ឈមណ្ឌលសង្គមកិច្ចព្រៃស្ពឺ នៅជាយរាជធានីភ្នំពេញ។ កង្វល់ខ្លាំងនៅតែមាន ពាក់ព័ន្ធនឹងការឃុំខ្លួន និងលក្ខខណ្ឌនៃការឃុំខ្លួនបុគ្គលទាំងឡាយ រាប់ទាំង កុមារ ជនវិកលចរិត ជនគ្មានផ្ទះសម្បែង និងជនមានផ្ទុកមេរោគហ៊ីវ/ជំងឺអេដស៍ នៅក្នុងមជ្ឈ

[1] នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០១២ អំឡុងពេលមានការវ៉ាមួយដោយកម្មករចំនួន ១៨០០ នាក់ នៅរោងចក្រកៅវ៉េ នៅក្រុងបាវិត ខេត្តស្វាយរៀង មានកម្មការិនី ចំនួន ៣ នាក់ ត្រូវបានគេបាញ់។ អភិបាលក្រុងបាវិត ត្រូវបានចោទប្រកាន់ទាក់ទងនឹងការបាញ់ទាំងនេះ។

មណ្ឌលសង្គមកិច្ចផ្សេងៗ ដូចជា មជ្ឈមណ្ឌលព្រៃស្ពឺ ដោយគ្មានការត្រួតពិនិត្យពីតុលាការ។ ការិយាល័យOHCHR កត់សម្គាល់ដោយក្តីពេញចិត្តថា ចាប់ពីខែមករា ឆ្នាំ២០១២ មក មជ្ឈមណ្ឌលព្រៃស្ពឺ មិនត្រូវបានគេប្រើប្រាស់ជាកន្លែងដាក់ឃុំមនុស្សដែលបានចាប់ប្រមូលតាមទំនើងចិត្ត ពីផ្លូវនានានៅរាជធានីភ្នំពេញទៀតឡើយ។ ប៉ុន្តែទោះជាដូច្នេះក្តី ក៏ការចាប់ប្រមូលមនុស្សដែលរស់នៅតាមផ្លូវនានា រាប់ទាំងកុមារផងដែរ នៅតែជាកង្វល់ ជាពិសេស នៅអំឡុងពេលមុនមានកិច្ចប្រជុំអន្តរជាតិធំៗនៅរាជធានីភ្នំពេញ មានជាអាទិ៍ ព្រឹត្តិការណ៍ផ្សេងៗអំពីអាស៊ាន។

២៨. នៅខែធ្នូ ឆ្នាំ២០១១ រដ្ឋាភិបាល បានចេញសេចក្តីព្រាងលើកទីបួនរបស់ខ្លួន នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល(ច្បាប់NGO)។ ការិយាល័យOHCHR បានផ្តល់យោបល់ជូនរដ្ឋាភិបាល អំពីភាពស្របគ្នានៃសេចក្តីព្រាងច្បាប់នេះជាមួយកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ និងបានបន្តគូសបញ្ជាក់អំពីសារៈសំខាន់ក្នុងការធានាឲ្យមានការពិគ្រោះយោបល់ទូលំទូលាយ និងប្រកបដោយអត្ថន័យ ជាមួយតួអង្គសង្គមស៊ីវិលផ្សេងៗ មុនការអនុម័តច្បាប់នេះ។ បន្ទាប់មក រដ្ឋាភិបាលបានកោះប្រជុំពិគ្រោះយោបល់មួយ រយៈពេលកន្លះថ្ងៃ ជាមួយតួអង្គសង្គមស៊ីវិល នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១១ ។ ច្បាប់នេះ នៅមិនទាន់បានអនុម័តនៅឡើយទេ ខណៈដែលកិច្ចប្រជុំពិគ្រោះយោបល់បន្ថែមទៀត ជាមួយតំណាងសង្គមស៊ីវិលនានា ត្រូវបានគ្រោងធ្វើ ដែលនេះជាសញ្ញាស្វាគមន៍នៃឆន្ទៈរបស់រដ្ឋាភិបាល ក្នុងការគិតគូពីកង្វល់របស់សង្គមស៊ីវិល។

## IV. សិទ្ធិដីធ្លី និងលំនៅដ្ឋាន

២៩. កម្មវិធីសិទ្ធិដីធ្លី និងលំនៅដ្ឋាន ធ្វើការជាមួយដៃគូពាក់ព័ន្ធទាំងអស់នៅក្នុងការឃ្លាំមើល ការលើកកំពស់ និងការអនុវត្តសិទ្ធិមានលំនៅដ្ឋានសមរម្យ និងបទដ្ឋានសមរម្យសំរាប់ការរស់នៅ ទប់ស្កាត់ការបណ្តេញចេញដោយបំពាន ព្រមទាំងការទទួលបានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី។ កម្មវិធីនេះ ធ្វើអន្តរាគមន៍ចំពោះហេតុការណ៍ដែលមានគំរាមកំហែង ការរំលោភបំពាន និងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងសហគមន៍ និងបុគ្គលគ្រប់រូបដែលធ្វើការទាមទារ សិទ្ធិដីធ្លី និងលំនៅដ្ឋានរបស់ខ្លួន និងអ្នកការពារសិទ្ធិមនុស្សនៅក្នុងវិស័យដីធ្លី។ ការិយាល័យ OHCHR ធ្វើការសហការជាមួយរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិលនានា សហគមន៍ សហគ្រាសពាណិជ្ជកម្ម និងសមាគមន៍វិជ្ជាជីវៈផ្សេងៗ ព្រមទាំងវិស័យអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគី ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ ដែលការពារការប្រើប្រាស់ដីធ្លី កម្មសិទ្ធិ និងសិទ្ធិលំនៅដ្ឋាន ព្រមទាំងបង្កើនការអនុវត្តឲ្យកាន់តែប្រសើរឡើងថែមទៀត ។

៣០. ការិយាល័យOHCHR ធ្វើសកម្មភាពរបស់ខ្លួន នៅក្នុងបរិបទដែលវិវាទដីធ្លីមានលក្ខណៈរីករាលដាល ការចាប់ទន្ទ្រានយកដីធ្លីធំៗដោយបុគ្គល ឬក្រុមអ្នកមានអំណាច (ជាញឹកញាប់ដោយមានការឃុបឃិតរបស់រដ្ឋ និងការសមគំនិតរបស់សហគ្រាសពាណិជ្ជកម្មទាំងក្នុងស្រុក និងបរទេស) សម្បទានដីសេដ្ឋកិច្ច គោលដៅកសិ-ឧស្សាហកម្ម (ដូចជា ចំការកៅស៊ូ ចំការអំពៅ ចំការដំឡូងមី) សម្បទានដីសំរាប់ការធ្វើអាជីវកម្មធនធានធម្មជាតិ (រាប់ទាំងតំបន់ការពារធម្មជាតិ) ដូចជា ការស្វែងរុករករ៉ែ និងនិស្សរណកម្មប្រេង និងទាក់ទាញទេសចរណ៍ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការទាញយកថាមពលជាលក្ខណៈឧស្សាហកម្ម (ឧទាហរណ៍ ទំនប់វារីអគ្គីសនី) ការអភិវឌ្ឍន៍ និងការបង្កើតជាថ្មីនូវតំបន់ទីប្រជុំជន ដែលមានចរិកលក្ខណៈជាការបណ្តេញចេញដោយបំពាន និងមិនមានផែនការសមស្របសំរាប់ការតាំងទីលំនៅថ្មី ។

៣១. ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ, ការិយាល័យOHCHR ត្រូវបានអំពាវនាវឲ្យផ្តល់ជំនួយក្នុងករណីវិវាទដីធ្លីចំនួន ៦៣ ករណី ដែលជាវិវាទរវាងសហគមន៍រងផលប៉ះពាល់ អាជ្ញាធរ និងក្រុមហ៊ុនពាណិជ្ជកម្ម ដែលក្នុង

នោះមាន ៣៧ ករណី គឺជារឿងក្តីពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត រាប់ទាំង ១១ ករណី ពាក់ព័ន្ធនឹងដីជនជាតិដើមភាគតិច[2]។ ករណីវិវាទចំនួន ២៦ ករណី ពាក់ព័ន្ធទៅនឹងការលក់ដូរដីធ្លី ដែលក្នុងនោះ ១ ករណីជាដីជនជាតិដើមភាគតិច[3]។ កិច្ចអន្តរាគមន៍របស់ការិយាល័យOHCHR ស្ថិតនៅក្នុងទម្រង់នៃការសម្របសម្រួល កិច្ចសន្ទនា និងការផ្តល់យោបល់ផ្នែកច្បាប់ និងនីតិវិធីច្បាប់ ។

៣២. ផ្អែកលើទស្សនវិស័យសិទ្ធិមនុស្ស ការិយាល័យOHCHR ឃ្លាំមើលយ៉ាងជិតដិតលើផលប៉ះពាល់នៃការផ្តល់ និងចាត់ចែងដីគោលដៅសម្បទានសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតដោយរដ្ឋាភិបាល។ ករណីដែលស្ថិតក្រោមការឃ្លាំមើល រួមមាន ដីសម្បទាន ដែលត្រូវបានផ្តល់នៅក្នុងតំបន់ការពារទេសភាព ដូចជា តំបន់ឧទ្យានជាតិ តំបន់ដែនជម្រកសត្វព្រៃ តំបន់ព្រៃការពារ និងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ។ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ សម្តេចនាយករដ្ឋមន្ត្រីបានចេញបទបញ្ជាផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងដាក់ឲ្យមានការពិនិត្យពិច័យយ៉ាងហ្មត់ចត់លើសម្បទានដីដែលមានស្រាប់ ក្នុងគោលដៅការពារផលប្រយោជន៍របស់សហគមន៍ ដែល

---

[2] រឿងក្តីទាំងនេះ មានដូចតទៅ ប៉ុន្តែមិនមែនមានតែចំនួននេះទេ ៖ នៅខេត្តមណ្ឌលគិរី ស្រុកពេជ្រាដា ឃុំប៊ូស្រា វិវាទរវាងសហគមន៍ជនជាតិដើមភាគតិច(ពួង) ចំនួន ៨០០ គ្រួសារ និងក្រុមហ៊ុនសុកហ្វីន ខេស៊ីឌី (Socfin-KCD) និងដៃគូ, នៅខេត្តក្រចេះ ស្រុកស្នួល ឃុំ ស្រែចារ វិវាទរវាងប្រជាពលរដ្ឋចំនួន ២២៤ គ្រួសារ និង ក្រុមហ៊ុនអភិវឌ្ឍន៍ស៊ីអាយវី (CIV), នៅខេត្តរតនៈគិរី ស្រុកលំផាត់ ឃុំសេដា វិវាទរវាងសហគមន៍ជនជាតិដើមភាគតិច(ទំពួន) ប្រមាណជា ៥០០ គ្រួសារ និងក្រុមហ៊ុន ជីញ ហ្សុងរី, នៅខេត្តក្រចេះ ស្រុកស្នួល ឃុំ ២ធ្នូ វិវាទរវាងប្រជាពលរដ្ឋប្រមាណជា ៦០០ គ្រួសារ និង ក្រុមហ៊ុន ធីធីវ៉ាយ (TTY) , នៅខេត្តកោះកុង ស្រុកគិរីសាគរ និងស្រុកបុទុមសាគរ វិវាទរវាងប្រជាពលរដ្ឋប្រមាណជា ១.០០០ គ្រួសារ និងក្រុមហ៊ុន Union Development Group, នៅខេត្តកំពង់ស្ពឺ ស្រុក ថ្ពង ឃុំអមលាំង វិវាទរវាងប្រជាពលរដ្ឋប្រមាណជាង ១.០០០ គ្រួសារ និងក្រុមហ៊ុន Phnom Penh Sugar និង ក្រុមហ៊ុន Kompong Speu Sugar, នៅខេត្តពោធិសាត់ ស្រុកក្រវ៉ាញ និងស្រុកក្រគរ វិវាទចំនួន ២ រវាងប្រជាពលរដ្ឋប្រមាណជា ៥.០០០ គ្រួសារ និងក្រុមហ៊ុនភាពីមិច, និងស្រុកវាលវែង ឃុំថ្មដារនិង វិវាទរវាងប្រជាពលរដ្ឋ ៥៧ គ្រួសារ និងក្រុមហ៊ុន MDS, នៅរាជធានីភ្នំពេញ ក្នុងសហគមន៍បឹងកក់ វិវាទរវាងប្រជាពលរដ្ឋចំនួន ៣.០០០ - ៤.០០០ គ្រួសារ និងក្រុមហ៊ុនស៊ូកាគូអ៊ីន, នៅខេត្តបាត់ដំបង ស្រុកភ្នំព្រឹក ឃុំសំពៅលូន វិវាទរវាងប្រជាពលរដ្ឋចំនួន ១.២០៣ គ្រួសារ និងក្រុមហ៊ុនសួនមានសម្បត្តិ ។

[3] រឿងក្តីទាំងនេះ មានដូចតទៅ ប៉ុន្តែមិនមែនមានតែចំនួននេះទេ ៖ នៅខេត្តរតនៈគិរី ស្រុកអូយ៉ាដាវ ឃុំប៉ាតេ ភូមិគងយុ វិវាទរវាងប្រជាពលរដ្ឋជាជនជាតិចារ៉ាយនៃសហគមន៍ជនជាតិដើមភាគតិចចំនួន ៤៦ គ្រួសារ និងភរិយារបស់មន្ត្រីរាជរដ្ឋាភិបាលមួយរូប, នៅខេត្តកណ្តាល ស្រុកកៀនស្វាយ ឃុំសំរោង វិវាទរវាងប្រជាពលរដ្ឋចំនួន ១៤៩ គ្រួសារ និងអភិបាលរងខេត្តក្រចេះ, នៅខេត្តកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច ឃុំតាជេស្ទ ភូមិឡពាង វិវាទរវាងប្រជាពលរដ្ឋចំនួន៦៤ គ្រួសារ និងក្រុមហ៊ុន KCD International, នៅខេត្តកំពង់ស្ពឺ ស្រុកឧត្តុង្គ ភូមិដំណាក់រាំង និងភូមិភ្នំតូច (ព្រំប្រទល់ខេត្តកណ្តាល) វិវាទរវាងប្រជាពលរដ្ឋចំនួន ៨៨ គ្រួសារ និងក្រុមហ៊ុន ម៉េង កេត, នៅខេត្តបាត់ដំបង ក្រុងបាត់ដំបង វិវាទរវាងប្រជាពលរដ្ឋចំនួន ៥៥ គ្រួសារ និងគម្រោងស្តារផ្លូវដែករបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB), នៅក្នុងសង្កាត់ព្រែកព្រះស្តេច វិវាទរវាងប្រជាពលរដ្ឋចំនួន ៣៣៤ គ្រួសារ និងអាជ្ញាធរខេត្ត (គម្រោងសួនច្បារ), នៅស្រុកសំឡូត ឃុំកំពង់ល្ពៅ វិវាទរវាងប្រជាពលរដ្ឋចំនួន ៧៨ គ្រួសារ និងប្រតិបត្តិការសឹកយោធភូមិភាគ ៥, និងស្រុកគាស់ក្រឡ ឃុំដូនបា និងឃុំព្រះផុស (៣ ករណី) វិវាទរវាងប្រជាពលរដ្ឋចំនួន ៥៥០ គ្រួសារ និងមន្ត្រីយោធា, នៅខេត្តបន្ទាយមានជ័យ ក្រុងប៉ោយប៉ែត វិវាទរវាងប្រជាពលរដ្ឋចំនួន៩៤៣ គ្រួសារ និងគម្រោងស្តារផ្លូវដែករបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB), នៅរាជធានីភ្នំពេញ សហគមន៍បុរីកីឡា វិវាទរវាងប្រជាពលរដ្ឋចំនួន១.៧៧៦ គ្រួសារ និងក្រុមហ៊ុនផានីមិច និងសហគមន៍ត្រពាំងអញ្ចាញ វិវាទរវាងប្រជាពលរដ្ឋចំនួន១៤៨ គ្រួសារ និងអាជ្ញាធរមូលដ្ឋាន ពាក់ព័ន្ធនឹងគម្រោងស្តារផ្លូវដែករបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

ការិយាល័យOHCHR សូមស្វាគមន៍។ ទោះជាយ៉ាងណាក៏ដោយ និតិវិធីសំរាប់អនុវត្តបទបញ្ញានេះ មានភាពស្រពិចស្រពិល ហើយងាយនឹងនាំមកនូវភាពមិនប្រក្រតីចំពោះករណីខ្លះ។

៣៣. ដោយសារតែការអនុវត្តក្របខណ្ឌច្បាប់ ដែលគ្របដណ្តប់លើសិទ្ធិដីធ្លី និងលំនៅដ្ឋាន មានភាពមិនប្រក្រតីនោះ មានបាតុកម្ម និងការតវ៉ាជាច្រើនពីសហគមន៍ដែលរងការប៉ះពាល់នៅក្នុងទីក្រុង និងតាមបណ្តាខេត្តនានា ដែលបានក្លាយជារឿងកាន់តែសាមញ្ញទៅហើយ នៅអំឡុងពេលធ្វើរបាយការណ៍នេះ។ ទោះជាទម្រង់នៃការតវ៉ា និងការសាមគ្គីគ្នាមានលក្ខណៈសន្តិវិធី បានប្រព្រឹត្តិទៅជាបន្ត ក៏មានការកើនឡើងនូវការប្រើប្រាស់វិធីផ្សេងៗ ដូចជា ការដោះសម្លៀកបំពាក់នៅទីសាធារណៈ ដើម្បីតវ៉ា ការដុតរូបសំណាក ការបិទផ្លូវជាតិ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ការចាប់ឃាត់ទុកឈើខុសច្បាប់ ការប្រឈមមុខបែបហិង្សាជាក់គ្នាជាមួយអាជ្ញាធរ និងជាមួយតួអង្គសាជីវកម្ម (រួមមានទាំង ករណីនៃការចាប់ជាចំណាប់ខ្មាំង) និងការកាន់ស្រាក់ដៃគ្នាជាជួរនៃអ្នកតវ៉ា ដែលទាំងអស់នេះ បង្ហាញជាសញ្ញាណនៃចំនួនប្រជាពលរដ្ឋគ្មានដីធ្លីដែលអស់សង្ឃឹម និងខឹងសម្បា មានការកើនឡើង។

៣៤. ការិយាល័យOHCHR បានអន្តរាគមន៍ ឃ្លាំមើល បាតុកម្ម និងការតវ៉ា ម្តងហើយម្តងទៀត ដើម្បីទប់ស្កាត់អំពើហិង្សា និងដើម្បីធ្វើឲ្យមានការដោះលែងប្រជាពលរដ្ឋដែលរងការចោទប្រកាន់ខុស ឬត្រូវឃុំខ្លួនដោយបំពាន។ ក្នុងចំណោមករណីវិវាទដីធ្លីចំនួន ៦៣ ដែលការិយាល័យOHCHR បានធ្វើការ ការិយាល័យOHCHR បានដឹងថា មានប្រជាពលរដ្ឋ ១៨២ នាក់ ត្រូវបានតុលាការកោះហៅទៅសាកសួរ (ករណីមួយចំនួន ជាករណីពាក់ព័ន្ធនឹងទំនាស់ដីធ្លីរ៉ាំរ៉ៃ) ដោយមានស្លានទម្ងន់ទោស ដែលភាគច្រើនពីបទផ្សាយព័ត៌មានមិនពិត ការរារាំងមន្ត្រីសាធារណៈ ការចូលកាន់កាប់មិនត្រឹមត្រូវតាមច្បាប់លើអចលនទ្រព្យ(ដី) ដែលជាទ្រព្យសម្បត្តិរបស់ស្ថាប័នសាធារណៈ(រដ្ឋ) ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ និងការចូលទន្ទ្រានកាន់កាប់ដីព្រៃ។ ក្នុងករណីមួយចំនួន បទចោទប្រកាន់នៅបន្តទុកពន្យាចោលនៅតុលាការ និងមានចំណាត់ការជាបន្តឡើងវិញ ចំពោះសំណុំរឿងមួយចំនួន ខណៈដែលក្នុងករណីខ្លះអ្នកភូមិត្រូវបានឃុំខ្លួន។ ការិយាល័យOHCHR បានជំរុញដល់ការធានាការអនុវត្តនិតិវិធីច្បាប់ត្រឹមត្រូវ ដែលជាលទ្ធផល ក្នុងករណីជាក់លាក់ខ្លះ មានបុគ្គលខ្លះត្រូវបានដោះលែង ។

៣៥. ស្ត្រី មនុស្សចាស់ និងកុមារ ជាញឹកញាប់ ស្ថិតនៅជួរមុខគេ នៅពេលធ្វើការតវ៉ា ដែលសហគមន៍គិតថាអាជ្ញាធរនឹងមិនធ្វើការបង្ក្រាបធ្ងន់ធ្ងរទៅលើស្ត្រី និងកុមារឡើយ។ ទោះជាយ៉ាងណាក៏ដោយ មានការកើនឡើងនូវករណីហិង្សាលើស្ត្រីក្នុងស្ថានភាពនៃការមានបាតុកម្ម និងមានការឃុំខ្លួនដោយបំពានលើអ្នកតវ៉ាជាស្ត្រី។ ស្ត្រីបន្តរងទុក្ខធ្ងន់ធ្ងរក្នុងពេលដំណើរការនៃការបណ្តេញចេញ និងការផ្លាស់ទីលំនៅថ្មី ដែលជាក់សម្ពាធលើជីវភាពរស់នៅ និងលើការថែទាំក្រុមគ្រួសារ។ អំពើហិង្សាក្នុងគ្រួសារនៅកន្លែងតាំងទីលំនៅថ្មី ក៏ដូចជាការមានផ្ទៃពោះដោយគ្មានការគ្រោងទុកត្រូវបានគេរាយការណ៍ថា មានភាពរីករាលដាល ។

៣៦. ការិយាល័យOHCHR ធ្វើការដើម្បីជួយដល់ការអភិវឌ្ឍន៍ជាបន្ត នូវការការពារផ្នែកនិតិវិធីនិងច្បាប់ ក៏ដូចជាការលើកកំពស់ដល់ការអនុវត្ត។ នៅដើមឆ្នាំ២០១០ រដ្ឋាភិបាលបានចេញពង្រាងគោលនយោបាយស្តីពីលំនៅដ្ឋាន ដែលគោលនយោបាយនេះនៅកំពុងតែរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រី។ ការិយាល័យOHCHR ត្រៀមខ្លួនជាស្រេច ដើម្បីជួយគាំទ្រដល់ការអនុវត្តគោលនយោបាយនេះ ជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការិយាល័យOHCHR បានផ្តល់យោបល់ដោយមានបញ្ចូលទិដ្ឋភាពសិទ្ធិមនុស្សផងដែរ លើសេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានផែនការចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាបន្តទៀត។

៣៧. ការិយាល័យOHCHR បន្តបញ្ចូលក្នុងកម្មវិធីសិទ្ធិដីធ្លី និងលំនៅដ្ឋានរបស់ខ្លួន នូវគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងជំរុញដល់ការទទួលខុសត្រូវរបស់រដ្ឋ ចំពោះការរំលោភសិទ្ធិមនុស្ស ប្រព្រឹត្តដោយភាគីទីបី។ ជាបន្ថែមទៀត ការិយាល័យOHCHR ធ្វើការជាមួយតួអង្គពាណិជ្ជកម្ម និងសមាគមវិជ្ជាជីវៈមួយចំនួន ដើម្បីលើកទឹកចិត្តពួកគេឲ្យអនុវត្តបទដ្ឋានសិទ្ធិមនុស្សនៅក្នុងសកម្មភាពរបស់ខ្លួន។ ក្នុងខែធ្នូ ឆ្នាំ២០១១ ការិយាល័យOHCHR បានរៀបចំពិធីផ្សព្វផ្សាយសៀវភៅបោះពុម្ពផ្សាយជាភាសារអង់គ្លេស និងខ្មែរ អំពីគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖ ការអនុវត្តក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពី "ការការពារ ការគោរព និងដំណោះស្រាយ"។[4] ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យOHCHR ចាត់ចែងរៀបចំឡើងនូវសិក្ខាសាលាស្តីពីសិទ្ធិមនុស្ស និងធុរកិច្ចសំរាប់អង្គការសង្គមស៊ីវិល (រាប់ទាំងការពន្យល់បង្ហាញខ្លីមួយ ទៅកាន់អង្គការនានាមកពីក្នុងតំបន់ នៅក្នុងវេទិកាប្រជាពលរដ្ឋអាស៊ាន) បុគ្គលិកបច្ចេកទេសរបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(CHRC) និងសមាជិករដ្ឋាភិបាលមកពីក្រសួងនានា (រួមមាន ការពន្យល់បង្ហាញភាពខុសគ្នាពីការទទួលខុសត្រូវសង្គមរបស់សាជីវកម្ម "CSR" របស់ធុរកិច្ច និងសិទ្ធិមនុស្ស) និងការអនុវត្តគោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្សនិងធុរកិច្ច ក្នុងបរិបទនៃកម្ពុជា។

៣៨. ក្នុងខែឧសភា ឆ្នាំ២០១០ បន្ទាប់ពីរដ្ឋាភិបាលអនុម័តសារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅតាមរាជធានី ទីក្រុង និងទីប្រជុំជន (សារាចរ ០៣) ។ ការិយាល័យOHCHR បានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ផ្តល់ជំនួយបច្ចេកទេសសំរាប់សហគមន៍ ដើម្បីធ្វើការកំណត់ព្រំប្រទល់ទីតាំងដីរបស់ខ្លួន និងកំណត់អំពីសេវាមូលដ្ឋាន និងតម្រូវការលើហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាស្វែងយល់ពីសិទ្ធិក្នុងការកាន់កាប់ដីធ្លីរបស់ខ្លួន ក្នុងក្របខណ្ឌច្បាប់កម្ពុជា។ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បន្តធ្វើការងារជាមួយអជ្ញាធរ សហគមន៍ និងដៃគូអភិវឌ្ឍន៍នានា នៅទីរួមខេត្តបាត់ដំបង ដើម្បីធានាដល់ការអភិវឌ្ឍន៍នៅនឹងកន្លែង និងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី។

៣៩. ដើម្បីជួយការពារដល់ជីវភាពរស់នៅតាមប្រពៃណី និងវប្បធម៌របស់ជនជាតិដើមភាគតិច ការិយាល័យ OHCHR គាំទ្របណ្តាញរដ្ឋាភិបាល អង្គការសហប្រជាជាតិនានា សង្គមស៊ីវិល និងសហគមន៍ ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេ ក្នុងការប្រើប្រាស់ក្របខ័ណ្ឌច្បាប់ក្នុងស្រុកទាក់ទងនឹងប័ណ្ណកម្មសិទ្ធិសមូហភាព។ ការិយាល័យOHCHR បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសដល់ភូមិចំនួន ៧ នៅក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគីរី ដែលមានជនជាតិព្នងរស់នៅ និងភូមិចំនួន ៥ នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺដែលមានជនជាតិសួយរស់នៅ ដើម្បីដំណើរការការចុះបញ្ជីជានីតិបុគ្គលជាមួយរដ្ឋាភិបាល ដែលជួយពួកគេស្នើសុំប័ណ្ណកម្មសិទ្ធិសមូហភាព នៅថ្ងៃអនាគត។ ការិយាល័យOHCHR ដោយសហការជាមួយក្រសួង អង្គការពលកម្មអន្តរជាតិ(ILO) និងអង្គការមិនមែនរដ្ឋាភិបាល ក៏បានឃ្លាំមើលគម្រោង ដែលមានជនជាតិព្នង ៨០០ គ្រួសារ និងជនជាតិសួយ ២៣៨ គ្រួសារ ធ្វើការការពារខ្លួន ពីការគំរាមកំហែងរបស់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀត ។

៤០. ក្រៅពីភាពជោគជ័យដ៏គួរកត់សំគាល់ក្នុងការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច ដើម្បីឈានទៅការចេញប័ណ្ណកម្មសិទ្ធិសមូហភាព ការរំលោភលើដីជនជាតិដើមភាគតិច មានទាំងការផ្តល់ដីសម្បទានផង បានរីករាលដាលលឿនជាងការបង្កើតនូវសុវត្ថិភាពខាងការកាន់កាប់ដីសំរាប់សហគមន៍ជាច្រើនបំផុត។ ការិយាល័យOHCHR សូមស្វាគមន៍ចំពោះការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចចំនួន ៣ សហគមន៍ ក្នុង

[4] សូមអាន A/HRC/17/31.

ខេត្តរតនគិរី និងមណ្ឌលគិរី ក្នុងខែធ្នូ ឆ្នាំ២០១១។ ការវិវឌ្ឍន៍ដ៏គួរកត់សំគាល់នេះ គឺជាការបង្ហាញឲ្យឃើញពីឆន្ទៈការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។ ទោះជាយ៉ាងណាក៏ដោយ ការខ្វះការអនុវត្តវិធានការការពារជាបណ្តោះអាសន្នសំរាប់សហគមន៍ទាំងអស់នោះ ដែលកំពុងតែស្ថិតក្នុងដំណើរការនៃការចុះបញ្ជី ហើយដែលជាដំណើរការមានពេលវេលាយូរ និងស្មុគ្រស្មាញ និងពឹងផ្អែកលើធនធានរបស់ម្ចាស់ជំនួយ បានទុកឲ្យសហគមន៍ជនជាតិដើមភាគតិចប្រឈមនឹងហានិភ័យនៃការដណ្តើមដីធ្លី និងការបាត់បង់មុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ដោយសារតែសម្បទានដី និងគម្រោងអភិវឌ្ឍន៍ផ្សេងៗ។

៤១. សំរាប់សហគមន៍ដែលត្រូវបានបណ្តេញចេញដោយបំពាន ការិយាល័យOHCHR បន្តជំរុញដល់ការតាំងទីលំនៅថ្មី ដែលមានការរៀបចំផែនការជាមុន ដើម្បីធ្វើឲ្យប្រសើរឡើងដល់ការអនុវត្តនាពេលបច្ចុប្បន្ននៃការផ្លាស់ទីលំនៅសហគមន៍ទៅកាន់ទីតាំងដែលខ្វះហេដ្ឋារចនាសម្ព័ន្ធ និងស្ថិតនៅឆ្ងាយពីឱកាសការងារ សាលារៀន និងមន្ទីរព្យាបាលជំងឺ។ ការិយាល័យOHCHR បន្តឃ្លាំមើលទីតាំងនៃការតាំងទីលំនៅថ្មីជាច្រើន ដែលរួមមានទាំងទីតាំងដែលមាននៅក្នុងការសិក្សារបស់ការិយាល័យOHCHR មានចំណងជើងថា "ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា៖ តម្លៃនៃផលប៉ះពាល់ និងឥទ្ធិពលចំពោះមនុស្ស និងដំណោះស្រាយ" ដែលពិនិត្យមើលឧទាហរណ៍មួយចំនួននៃការបណ្តេញចេញ និងការផ្លាស់ទីលំនៅថ្មី ដែលវាមានទាំងកត្តាវិជ្ជមាន និងអវិជ្ជមាន និងវិភាគអំពីផលប៉ះពាល់របស់វាលើលក្ខខណ្ឌរស់នៅរបស់គ្រួសារដែលរងការប៉ះពាល់។ ការសិក្សានេះ ត្រូវបានចែកជូនរដ្ឋាភិបាលដើម្បីឲ្យផ្តល់យោបល់ និងបានទទួលមតិយោបល់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការិយាល័យOHCHR ឃ្លាំមើលផងដែរ នូវគម្រោងស្តារផ្លូវដែកឡើងវិញ ដោយធ្វើការសហការជាមួយអាជ្ញាធរ ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) និងសហគមន៍ដែលរងផលប៉ះពាល់។

## V. នីតិរដ្ឋ

៤២. វឌ្ឍភាពនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅមានការយឺតយ៉ាវនៅឡើយក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ ក្រសួងយុត្តិធម៌ និងតុលាការ បន្តទទួលរងនូវកង្វះខាតធនធានជាច្រើន។ ការគោរពនីតិរដ្ឋ ត្រូវបានរារាំងផងដែរ ដោយការអះអាងគួរឲ្យជឿបានថា មានការជ្រៀតជ្រែកពីអំណាចនីតិប្រតិបត្តិទៅក្នុងប្រព័ន្ធតុលាការ និងអំពើពុករលួយដែលមានលក្ខណៈរីករាលដាល។ ជាលទ្ធផល និទណ្ឌភាពចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ នៅតែបន្តមាន ហើយការជឿទុកចិត្តពីសាធារណជន ទៅលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ នៅមិនទាន់មានភាពប្រសើរនៅឡើយ។ ទោះជាមានការអះអាងផ្ទុយពីនេះក្នុងឆ្នាំ២០១២ ក្តី ក៏ដំណើរការនៃការអនុម័តច្បាប់គន្លឹះ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ (ដូចជា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម) នៅតែជាប់គាំងនៅឡើយ ដោយមានហេតុផលមិនច្បាស់លាស់។ ការិយាល័យOHCHR នៅតែយល់ឃើញថា ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌របស់កម្ពុជានឹងប្រសើរឡើងទៅបានលុះត្រាតែមានច្បាប់គន្លឹះទាំងអស់នេះ។

៤៣. ទោះជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ អង្គភាពនីតិរដ្ឋនៃការិយាល័យOHCHR បានបន្តជួយអាជ្ញាធរមេធាវី និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឲ្យប្រសើរឡើងដល់ការការពារសិទ្ធិមនុស្សនៅកម្ពុជា តាមរយៈប្រព័ន្ធយុត្តិធម៌។

៤៤. ការិយាល័យ OHCHR ដើរតួនាទីយ៉ាងសំខាន់ ក្នុងការពង្រឹងនីតិរដ្ឋ តាមរយៈការជំរុញលើកទឹកចិត្តឲ្យមានការផ្តល់សច្ចាប័នលើលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងៗ។ ដើម្បីសំរេចគោលដៅនេះ អង្គភាពនីតិរដ្ឋបានបន្តផ្តល់យោបល់ជូនរដ្ឋាភិបាល ដែលបានប្រកាសពីបំណងប្រាថ្នារបស់ខ្លួនថានឹងផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ ដើម្បីលើកកំពស់ការយល់ដឹងអំពីអនុសញ្ញានេះ ជាពិសេសក្នុងចំណោមជនពិការ ការិយាល័យOHCHR បានបោះពុម្ពសំណៅនៃអនុសញ្ញានេះ ជាសម្រាយនិងជាសំលេង។ ការិយាល័យOHCHR បានធ្វើបទបង្ហាញជាច្រើនផងដែរអំពីអនុសញ្ញានេះដល់តួអង្គនានា ក្នុងសង្គមស៊ីវិល។

៤៥. ដោយសារបញ្ហានៃការការពារសិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើការនៅបរទេស បានទាក់ទាញការយកចិត្តទុកដាក់ខ្លាំងក្នុងរយៈពេល ១ ឆ្នាំ ចុងក្រោយនេះ អង្គភាពនីតិរដ្ឋបានបកប្រែជាភាសាខ្មែរនូវអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ។ អនុសញ្ញាជាភាសាខ្មែរនេះ ត្រូវបានដាក់ឲ្យប្រើប្រាស់កាលពីខែមីនា ឆ្នាំ២០១២ ដោយមានធ្វើពិធីផ្សព្វផ្សាយមួយ ដែលបានរៀបចំឡើងដោយមានកិច្ចសហការជាមួយអង្គការសហប្រជាជាតិដើម្បីស្ត្រី(UN-WOMEN)។ ពិធីនេះ បានប្រព្រឹត្តិទៅក្រោមអធិបតីភាពលោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមានការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើន រួមមាន មន្ត្រីរដ្ឋាភិបាល សង្គមស៊ីវិល តំណាងពីភ្នាក់ងារជ្រើសរើសពលករ តំណាងសហជីព និងអ្នកសារព័ត៌មាន។ សមាជិកមួយរូប នៃគណៈកម្មាធិការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ក៏បានអញ្ជើញចូលរួមក្នុងពិធីនេះផងដែរ។ បន្ទាប់ពីពិធីនេះ អាជ្ញាធរបានបញ្ជាក់ថា នឹងមានកិច្ចពិភាក្សាអន្តរក្រសួងមួយ ពិភាក្សាអំពីលទ្ធភាពដែលកម្ពុជានឹងផ្តល់សច្ចាប័នលើអនុសញ្ញានេះ។ នៅទីបញ្ចប់ អង្គភាពនីតិរដ្ឋ បានជំរុញលើកទឹកចិត្តដល់រដ្ឋាភិបាលឲ្យពិចារណាពីការផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពាក់ព័ន្ធនឹងការលប់បំបាត់ទោសប្រហារជីវិត ស្របតាមអនុសាសន៍ UPR។ ដោយមានសំណើពីរដ្ឋាភិបាល ការិយាល័យ OHCHR បានរៀបចំកិច្ចប្រជុំបច្ចេកទេសមួយ ដើម្បីពិភាក្សាកាន់តែលំអិតថែមទៀត អំពីបទបញ្ញត្តិនានានៃពិធីសារបន្ថែមនេះទី១ និងពិធីសារបន្ថែមទី២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងពិធីសារបន្ថែមទី៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

៤៦. ការិយាល័យ OHCHR បន្តជំរុញលើកទឹកចិត្តដល់ការអនុវត្តច្បាប់ជាតិដែលមានស្រាប់ ស្របតាមបទដ្ឋានសិទ្ធិមនុស្សនានា ដោយផ្តោតលើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ ដើម្បីសម្រេចគោលដៅនេះ សមាជិកកម្មវិធីនីតិរដ្ឋជួបប្រជុំជាទៀងទាត់ ជាមួយប្រធានតុលាការ និងព្រះរាជអាជ្ញា នៅតាមសាលាដំបូងខេត្ត-រាជធានី ដើម្បីពិភាក្សាពីបញ្ហាប្រឈមនានា ដែលបានជួបប្រទះក្នុងការអនុវត្តក្រមនេះ និងក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ជាទូទៅ។ កិច្ចពិភាក្សាតុមូលផ្នែកតុលាការមួយចំនួន ត្រូវបានរៀបចំឡើងនៅតាមបណ្តាខេត្ត ដើម្បីពិភាក្សាពីបញ្ហាប្រឈមទាំងនេះ ដោយប្រើប្រាស់ឧទាហរណ៍ពីទំលាប់អនុវត្តនៅ អ.វ.ត.ក ជាដើម ក្នុងករណីដែលសមស្រប។ ស្របគ្នានេះ ការិយាល័យOHCHR បានឧបត្ថម្ភការប្រជុំជាទៀងទាត់ រវាងមន្ត្រីនគរបាលយុត្តិធម៌ តុលាការ និងពន្ធនាគារនៅក្នុងខេត្តនាទិសពាយ័ព្យមួយចំនួន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងពិភាក្សាពីបញ្ហានានាទាក់ទងនឹងការអនុវត្តក្រមនេះ។ ការិយាល័យOHCHR បានផ្តល់ជំនួយក្នុងការឃ្លាំមើលតុលាការក្នុងខេត្តចំនួន ២ ធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ក្នុងគោលបំណងបង្កើនការត្រួតពិនិត្យមើលជាសាធារណៈលើសវនាការរឿងក្តីព្រហ្មទណ្ឌ។ នៅទីបំផុត ការិយាល័យ OHCHR ដោយសហការជាមួយក្រសួងយុត្តិធម៌ បានរៀបចំសន្និសីទថ្នាក់ជាតិដ៏ធំមួយនៅចុងខែមិថុនាឆ្នាំ២០១២ ស្តីពីការពិនិត្យមើលការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមានការចូលរួមពីចៅក្រម ព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ មេធាវី មន្ត្រីរដ្ឋាភិបាល និងតំណាងអង្គការមិនមែនរដ្ឋាភិបាលនានាចំនួន ១៦៥ នាក់មកពីគ្រប់ខេត្ត-រាជធានី ។

៤៧. ក្រៅពីការឃ្លាំមើលការអនុវត្តច្បាប់ដែលមានស្រាប់ ការិយាល័យOHCHR បន្តជួយរដ្ឋាភិបាល ក្នុងការអនុម័តច្បាប់ថ្មីៗ ស្របតាមកាតព្វកិច្ចសិទ្ធិមនុស្ស។ ជាឧទាហរណ៍មួយ តាមរយៈសកម្មភាពនេះ ការិយាល័យOHCHR ដោយមានការពិគ្រោះយោបល់ជាមួយមូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ(UNICEF) បានធ្វើអនុសាសន៍លើសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធយុត្តិធម៌អនីតិជន។

៤៨. ការិយាល័យ OHCHR នៅតែមានកង្វល់អំពីសិទ្ធិទទួលបាននូវយុត្តិធម៌ ជាពិសេស សំរាប់ជនក្រីក្រ និងក្រុមងាយរងគ្រោះផ្សេងៗដ៏ទៃទៀត។ សេវាកម្មជំនួយផ្នែកច្បាប់ បន្តទទួលរងនូវការខ្វះខាតមូលនិធិយ៉ាងធ្ងន់ធ្ងរ។ បើទោះជាក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវថា ជនគ្រប់រូបដែលចោទប្រកាន់ពីបទឧក្រិដ្ឋ និងអនីតិជន ត្រូវតែមានមេធាវីការពារក្តី ក៏តំណាងផ្លូវច្បាប់ ជារឿយៗ មិនអាចទទួលបាននោះឡើយ។ ការិយាល័យOHCHR បានបង្កើតដៃគូជាមួយក្រុមមេធាវីគ្មានព្រំដែន (ASF) ដោយមានគោលដៅផ្តល់ជំនួយផ្នែកច្បាប់ដល់ជនជាប់ចោទក្រីក្រនៅទូទាំងប្រទេសកម្ពុជា។ ស្របគ្នានេះដែរ ការិយាល័យOHCHR បានបន្តរៀបចំវគ្គបណ្តុះបណ្តាលសំរាប់អង្គការមិនមែនរដ្ឋាភិបាលនានា ដែលធ្វើការលើបញ្ហាស្ត្រី អំពីការប្រើប្រាស់នីតិវិធីបណ្តឹងបុគ្គល តាមពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ(OP-CEDAW)។ វគ្គបណ្តុះបណ្តាលទាំងនេះ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការជាមួយអង្គការសហប្រជាជាតិ ដើម្បីស្ត្រី(UN Women)។ ការិយាល័យOHCHR ក៏បានផលិតខិតប័ណ្ណពន្យល់អំពីវិធីប្រើប្រាស់នីតិវិធីបណ្តឹងខាងលើនេះផងដែរ។

៤៩. មេធាវីជាតួអង្គមួយ រួមចំណែកយ៉ាងសំខាន់ ដើម្បីធានាសិទ្ធិទទួលបានសេវាកម្មយុត្តិធម៌។ កម្មវិធីនីតិរដ្ឋបានបន្តជួយដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើឲ្យប្រសើរឡើងនូវបទដ្ឋានផ្សេងៗក្នុងវិជ្ជាជីវៈច្បាប់។ ការិយាល័យOHCHR បានជួលទីប្រឹក្សាមួយរូប ដើម្បីពិនិត្យលើច្បាប់លក្ខន្តិកៈមេធាវី ក្រមសីលធម៌វិជ្ជាជីវៈមេធាវី និងបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវី តាមទស្សនៈវិស័យនៃបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងពង្រាងសៀវភៅណែនាំថ្មីស្តីពីប្រតិបត្តិការរបស់គណៈមេធាវីផងដែរ។ អត្ថបទទាំងបួននេះ ត្រូវបានបញ្ជូនទៅសមាជិកគណៈមេធាវីទាំងអស់ និងបានបង្ហោះលើគេហទំព័ររបស់គណៈមេធាវីរួចហើយ ដើម្បីស្នើឲ្យមានការផ្តល់មតិយោបល់។ លើសពីនេះទៀត កម្មវិធីនេះ បានរៀបចំកិច្ចប្រជុំជាឈុតៗសំរាប់ក្រុមប្រឹក្សាគណៈមេធាវី ធ្វើការពិភាក្សាលើសំណើកែប្រែក្រមសីលធម៌វិជ្ជាជីវៈមេធាវី ហើយនិងធ្វើបញ្ចប់នូវអត្ថបទនេះ សំរាប់ការអនុម័ត។ ម្យ៉ាងវិញទៀត ការិយាល័យ OHCHR នាពេលថ្មីៗនេះ បានជ្រើសរើសមន្រ្តីតស៊ូមតិផ្នែកច្បាប់មួយរូប ដែលមានតួនាទីជួយដល់មេធាវីក្នុងការរៀបចំអំណះអំណាងផ្អែកតាមសិទ្ធិមនុស្សនៅចំពោះមុខតុលាការ និងក្នុងការស្វែងរកយុត្តិសាស្រ្តការពារក្តី។

៥០. ការជួយអាជ្ញាធរជាតិ ក្នុងការស៊ើបអង្កេតករណីនៃប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន នៅតាមទីកន្លែងឃុំខ្លួននៅតែជាបញ្ហាអាទិភាពមួយ។ ការិយាល័យOHCHR បន្តស៊ើបអង្កេតការចោទប្រកាន់អំពីប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួននៅតាមទីកន្លែងឃុំខ្លួននានា និងបន្តចូលរួមក្នុងកិច្ចសន្ទនាជាមួយអាជ្ញាធរ។ ម្យ៉ាងវិញទៀត ការិយាល័យOHCHR បានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត ដើម្បីជួយបង្ការអំពើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន។ ទីមួយ ដោយសារតែប្រទេសកម្ពុជា ជារដ្ឋភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម ដែលតម្រូវឲ្យបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិមួយ ការិយាល័យOHCHR បានបន្តផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាលក្នុងវិស័យនេះ។ សន្និសីទមួយ ស្តីពីការបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិ ត្រូវបានរៀបចំឡើងនៅអំឡុងខែវិច្ឆិកា ឆ្នាំ២០១១ ដែលមានសមាជិកអនុគណៈកម្មាធិការបង្ការទារុណកម្មចំនួនពីររូប បានមកចូលរួម និងផ្តល់យោបល់ដល់អាជ្ញាធរ។

ចាប់តាំងពីពេលនោះមក រដ្ឋាភិបាលបានប្តេជ្ញាចិត្តថានឹងធ្វើសេចក្តីព្រាងច្បាប់ថ្មីមួយ ដើម្បីបង្កើតយន្តការបង្ការថ្នាក់ជាតិនេះឡើង។

៥១. ទីពីរ ការិយាល័យOHCHR បានបន្តផ្តល់ការគាំទ្រដល់ស្ថាប័នអន្តរក្រសួង ដែលត្រូវបានបង្កើតជាស្ថាប័ននាំមុខ ឈានទៅរកការបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិមួយ(NPM)។ ជាពិសេស វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងសំរាប់សមាជិកគណៈកម្មាធិការអន្តរក្រសួងនេះ និងលេខាធិការដ្ឋានរបស់ខ្លួនស្តីពីរបៀប ចុះបំពេញទស្សនកិច្ចបង្ការទារុណកម្មទៅកាន់ទីកន្លែងឃុំខ្លួនទាំងឡាយ។ អាណត្តិការងាររបស់ពួកគេ ត្រូវបានលើកមកធ្វើជាបទបង្ហាញ និងពន្យល់ដល់ស្នងការនគរបាល និងមេបញ្ជាការកងរាជអាវុធហត្ថ ព្រមទាំង ប្រធានពន្ធនាគារទាំងអស់ មកពីគ្រប់ខេត្តក្រុង-រាជធានី ក្នុងសន្និសីទថ្នាក់ជាតិមួយ ដែលត្រូវបានរៀបចំឡើងនៅក្រសួងមហាផ្ទៃ នៅអំឡុងខែធ្នូឆ្នាំ២០១១។ ក្រោយមក គណៈកម្មាធិការអន្តរក្រសួងនេះ បានចាប់ផ្តើមកម្មវិធីធ្វើទស្សនកិច្ចទៅកាន់ពន្ធនាគារមួយចំនួន។ លើសពីនេះទៅទៀត ការិយាល័យOHCHR បានបន្តផ្តល់ការគាំទ្រដល់មហាអយ្យការអមសាលាឧទ្ធរណ៍ ដើម្បីចុះធ្វើទស្សនកិច្ចទៅកាន់ទីកន្លែងឃុំខ្លួនទាំងឡាយ ព្រមទាំងបានចូលរួមជាមួយអគ្គព្រះរាជអាជ្ញាក្នុងដំណើរទស្សនកិច្ចបែបនេះ បានចំនួនមួយលើក។

៥២. ទីបី ដោយមានការសហការជាមួយបណ្តាព្រះរាជអាជ្ញា កម្មវិធីនីតិរដ្ឋបានចាប់ផ្តើមរៀបចំវគ្គបណ្តុះបណ្តាលមួយចំនួននៅតាមបណ្តាខេត្ត សំរាប់មន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថស្តីពីការបង្ការ ការស៊ើបអង្កេត និងការចោទប្រកាន់អំពើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន។ នៅទីបំផុត ដោយសារតែក្រមនីតិវិធីព្រហ្មទណ្ឌធានាការពារនូវសិទ្ធិទទួលបានមេធាវីក្រោយចិរវេលា ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនដោយនគរបាលយុត្តិធម៌ ហើយនឹងយល់ឃើញថាករណីចំនួនច្រើនបំផុតនៃអំពើឃោរឃៅដោយមន្ត្រីនគរបាល កើតឡើងនៅក្នុងអំឡុងពេល ២៤ ម៉ោងទាំងនេះ ទើបការិយាល័យ OHCHR ដោយមានការសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ បានបង្កើតប័ណ្ណផ្សព្វផ្សាយអំពីសិទ្ធិពេលឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងគោលបំណងប្រាប់បុគ្គលដែលត្រូវចាប់ ឬឃាត់ខ្លួនឲ្យបានដឹងនូវសិទ្ធិទាំងឡាយរបស់ពួកគេ។ ប័ណ្ណនេះនឹងត្រូវធ្វើការផ្សព្វផ្សាយនៅតាមអង្គភាពនគរបាលទូទាំងប្រទេស។

៥៣. បទដ្ឋាននានាស្តីពីការជំនុំជម្រះក្តីដោយយុត្តិធម៌ តម្រូវឲ្យមានការសម្រេចលើបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេលសមហេតុសមផលមួយ។ ជនជាប់ឃុំភាគច្រើនរង់ចាំការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ដែលលើសនីតិវិធី។ សូម្បីតែក្រមនីតិវិធីព្រហ្មទណ្ឌ តម្រូវឲ្យបន្តឃុំខ្លួនជនជាប់ឃុំបន្ទាប់ពីផុតកំណត់ទោសរបស់ពួកគេ នៅពេលបណ្តឹងឧទ្ធរណ៍ដែលធ្វើដោយព្រះរាជអាជ្ញាមិនទាន់បានសំរេចនៅឡើយ។ ការិយាល័យOHCHR បច្ចុប្បន្នកំពុងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយសាលាឧទ្ធរណ៍ ដើម្បីកាត់បន្ថយការកកស្ទះនៃសំណុំរឿងជាប់បណ្តឹងឧទ្ធរណ៍ទាំងនេះដែលមិនទាន់ដោះស្រាយ។ ជាជំហានដំបូង ទិន្នន័យស្តីពីសំណុំរឿងជាប់បណ្តឹងឧទ្ធរណ៍មិនទាន់សម្រេច ដែលត្រូវបានប្រមូលពីបណ្តាពន្ធនាគារនៅអំឡុងឆ្នាំ ២០១១ គឺកំពុងត្រូវបានពិនិត្យផ្ទៀងផ្ទាត់ទៅនឹងព័ត៌មានដែលមាននៅសាលាឧទ្ធរណ៍ និងនៅតាមសាលាដំបូងមួយចំនួន។ ស្របគ្នានេះដែរការិយាល័យOHCHR និងប្រធានសាលាឧទ្ធរណ៍នឹងរៀបចំសិក្ខាសាលារួមគ្នាមួយនៅខែសីហា ឆ្នាំ២០១២ ដើម្បីពិភាក្សាអំពីការបង្កើនកិច្ចសហការរវាងអាជ្ញាធរតុលាការ និងអាជ្ញាធរពន្ធនាគារក្នុងន័យធ្វើឲ្យប្រសើរឡើង និងពន្លឿនដំណើរការបណ្តឹងឧទ្ធរណ៍។ អគារថ្មីនៅសាលាឧទ្ធរណ៍ដែលត្រូវបានសាងសង់បន្ទាប់ពីមានសំណើរបស់ការិយាល័យOHCHR (ហើយនិងមានការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលអូស្ត្រាលី និងការិយាល័យOHCHR) ត្រូវបានសាងសង់បញ្ចប់រួចរាល់នៅអំឡុងពេលកំពុងធ្វើរបាយការណ៍នេះ។

៥៤. អ.វ.ត.ក បានបន្តធ្វើឲ្យមានភាពជឿនលឿនគួរឲ្យកត់សំគាល់ ឆ្ពោះទៅរកការបញ្ចប់សំណុំរឿងចំនួន ២ ករណីរបស់ខ្លួនលើកដំបូង។ អង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីកាក្នុងសំណុំរឿងរបស់*កាំង ហ្គេច អ៊ាវ ហៅ "ឌុច"* (សំណុំរឿង ០០១) កាលពីខែមីនាឆ្នាំ ២០១២ ដោយផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើឲ្យមានភាពជឿនលឿនក្នុងសំណុំរឿង ០០២ ផងដែរ ដែលនៅក្នុងនោះអតីតមេដឹកនាំទាំង ៣ នាក់របស់គណបក្សកុម្មុយនិស្តកម្ពុជាកំពុងត្រូវបានកាត់ទោស។

៥៥. ទោះបីជាទទួលបានការកោតសរសើរជាទូទៅចំពោះសាលដីកាស្ថាពរក្នុងសំណុំរឿង ០០១ ក្តី ក៏ការិយាល័យ OHCHR មានកង្វល់ដោយកត់សំគាល់ឃើញថា ចៅក្រមភាគច្រើនបានទាត់ចោលនូវទិដ្ឋភាពផ្នែកសិទ្ធិមនុស្សដ៏មានសារសំខាន់មួយក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង៖ ពោលគឺអង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាត់ចេញនូវរយៈពេល ៥ ឆ្នាំ ពីទោសរបស់ ឌុច ជាសំណងទូទាត់សំរាប់រយៈពេលអូសបន្លាយ ដែលគាត់បានចំណាយក្នុងការឃុំខ្លួនមុនដំណាក់កាលជំនុំជម្រះក្តី។ ការសម្រេចចិត្តរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ហានេះ អាចដើរតួជាគំរូដ៏មានសារសំខាន់មួយ សំរាប់វិស័យថ្នាក់ជាតិរបស់តុលាការកម្ពុជា ដោយធានាបាននូវការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីមួយដោយមិនពន្យារពេល ដោយមិនគិតពីបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ ឬជនជាប់ចោទដែលត្រូវផ្តន្ទាទោសឡើយ។

៥៦. លើសពីនេះទៀត ការចោទប្រកាន់ទាំងឡាយអំពីការជ្រៀតជ្រែកផ្នែកនយោបាយ និងកិរិយាមិនត្រឹមត្រូវរបស់តុលាការទាក់ទងនឹងសំណុំរឿងបន្ថែម ២ ទៀត បានបន្តធ្វើឲ្យសៅហ្មងដល់កិត្តិយសរបស់ស្ថាប័នតុលាការ និងធ្វើឲ្យអន្តរាយដល់ភាពគួរឲ្យជឿជាក់បានក្នុងដំណើរការស៊ើបអង្កេតដែលខ្លួនកំពុងបន្តធ្វើ។ ស្ថានភាពធ្លាក់ចុះនៃកិត្តិយសរបស់ស្ថាប័ន អ.វ.ត.ក កាន់តែមានភាពធ្ងន់ធ្ងរថែមទៀត ដោយសារកង្វះការគាំទ្រពីរដ្ឋជាសមាជិកក្នុងការបន្តផ្តល់មូលនិធិដល់តុលាការ ដែលជាការដាក់សម្ពាធគួរឲ្យកត់សំគាល់ទៅលើបុគ្គលិកជាតិ និងអន្តរជាតិរបស់ស្ថាប័ននេះក្នុងការបំពេញអាណត្តិការងាររបស់តុលាការ ដោយប្រើប្រាស់ធនធានដ៏មានកំរិត ហើយនឹងបណ្តាលឲ្យមានការបញ្ឈប់សកម្មភាពនានានៃគេហ្គដំណែលរបស់តុលាការ ដែលបានគ្រោងទុកក្នុងគម្រោងថវិកាឆ្នាំ ២០១២-២០១៣។

៥៧. ការវិវឌ្ឍន៍ខាងលើនេះបានធ្វើឲ្យមានបញ្ហាប្រឈមថែមទៀតសំរាប់ការិយាល័យOHCHR ដើម្បីដំណើរការកម្មវិធីរបស់ខ្លួនក្នុងការលើកកម្ពស់កេរ្តិ៍ដំណែលរបស់ អ.វ.ត.ក។ ទោះបីយ៉ាងណាក៏ដោយផ្នែកសំខាន់ៗនៃកម្មវិធីនេះបានបន្តដំណើរការជឿនលឿនទៅមុខ។ ជាពិសេសកិច្ចសហការដែលកាន់តែកើនឡើងរវាងការិយាល័យOHCHR និងក្រសួងយុត្តិធម៌ នាំឲ្យមានការរៀបចំរួមគ្នានូវកិច្ចពិភាក្សាតុមូលផ្នែកតុលាការមួយឈុតជាមួយសាលាដំបូងខេត្តចំនួន ៥ ដោយមានចៅក្រម ព្រះរាជអាជ្ញា និងមេធាវីមកពីខេត្តចំនួន ១៤ ក្នុងចំណោមខេត្តទាំង ២៤ របស់ប្រទេសកម្ពុជាបានមកចូលរួមកិច្ចប្រជុំទាំងនេះ។ គោលបំណងបឋមនៃកិច្ចពិភាក្សាទាំងនេះ គឺដើម្បីធ្វើការពិនិត្យមើលមេរៀននានាដែលបានរៀនសូត្រ និងទទួលបានពីបទពិសោធន៍របស់ អ.វ.ត.ក ក្នុងបរិបទយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុក ក៏ដូចជាបញ្ហាទាំងឡាយនៃក្តីកង្វល់ដ៏ទូលំទូលាយ។ កិច្ចប្រជុំទាំងនេះគឺជាច្រកមួយដ៏មានសារសំខាន់ សំរាប់កិច្ចពិភាក្សាលើបញ្ហាច្បាប់មួយចំនួន ផ្អែកលើបរិបទនេះវិធានផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់ អ.វ.ត.ក ផ្តល់នូវគំរូនានាក្នុងការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ជាពិសេសបទបញ្ញត្តិទាំងឡាយ ដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន វិធាននៃភស្តុតាងព្រមទាំងនីតិវិធី។ លើសពីនេះទៀតការងារកំពុងបន្តធ្វើទាក់ទងនឹងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអមដោយសេចក្តីពន្យល់អំពីករណីយុត្តិសាស្ត្ររបស់ អ.វ.ត.ក នឹងធានាថាត្រូវតែរៀនសូត្រ និងទទួលយកបទពិសោធន៍/មេរៀនទាំងនេះទុកសំរាប់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីជំនាន់ក្រោយៗ។

៥៨. ក្នុងការប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តរបស់ការិយាល័យOHCHR ដើម្បីគាំទ្រនូវការលើកកំពស់ការយល់ដឹងអំពីហិង្សាផ្លូវភេទជាសកល ការិយាល័យOHCHR ប្រចាំប្រទេសកម្ពុជាគឺជាសមាជិកនៃគណៈកម្មាធិការប្រឹក្សាយោបល់សំរាប់ស្តាប់សម្លេងស្ត្រីស្តីពីហិង្សាផ្លូវភេទនៅអំឡុងពេលរបបខ្មែរក្រហម ដែលជាកិច្ចផ្តួចផ្តើមគំនិតមួយនៃគំរោងរបស់អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា(CDP)។ ការស្តាប់សម្លេងស្ត្រីត្រូវបានធ្វើឡើងជាលើកដំបូងកាលពីខែធ្នូ ឆ្នាំ២០១១ ដែលផ្តល់នូវមធ្យោបាយមួយសំរាប់ការចងក្រងជាឯកសារដ៏ទូលំទូលាយនូវកិច្ចពិភាក្សា និងសំរាប់កិច្ចពិភាក្សាអំពីហិង្សាផ្លូវភេទ ដែលបានប្រព្រឹត្តឡើងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយចងចាំទុកថាអំពីហិង្សាផ្លូវភេទនេះបានបង្កើត ហើយនឹងបង្កើតជាផ្នែកមួយនៃភស្តុតាងក្នុងវិសាលភាពដ៏មានកំរិត ដែលត្រូវបានស្តាប់យកចម្លើយនៅចំពោះមុខ អ.វ.ត.ក។ ការិយាល័យOHCHR កំពុងធ្វើការងារលើកិច្ចផ្តួចផ្តើមគំនិតនេះជាមួយអង្គការសហប្រជាជាតិសំរាប់ស្ត្រី ការិយាល័យតំណាងពិសេសរបស់អគ្គលេខាធិការស្តីពីហិង្សាផ្លូវភេទក្នុងជំលោះ និងជាមួយសង្គមស៊ីវិល។

## VI. ព័ត៌មានសាធារណៈ និងការអប់រំសិទ្ធិមនុស្ស

៥៩. កម្មវិធីផ្សព្វផ្សាយព័ត៌មានរបស់ការិយាល័យ OHCHR លើកកំពស់ការអប់រំ និងការយល់ដឹងអំពីសិទ្ធិមនុស្សក្នុងចំណោមក្រុមចម្រុះមួយ នៃអ្នកពាក់ព័ន្ធទាំងឡាយនៅទូទាំងប្រទេសកម្ពុជា។ កម្មវិធីនេះ ប្រើប្រាស់វិធីសាស្ត្រ និងឧបករណ៍ផ្សេងៗក្នុងការបញ្ជូនដំណឹង ដើម្បីពង្រីកការយល់ដឹងដល់សាធារណៈជនអំពីសិទ្ធិមនុស្ស និងធ្វើការក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល ទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ ក្រសួង-មន្ទីរក្នុងរដ្ឋាភិបាល និងគ្រឹះស្ថានសិក្សាផ្សេងៗ ។

៦០. ការិយាល័យOHCHR មានការងារមួយ ដែលផ្តោតសំខាន់លើការផ្សព្វផ្សាយកម្រងឯកសារបោះពុម្ពផ្សាយ ដើម្បីលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស។ ការិយាល័យOHCHR បានប្រគល់សៀវភៅជាង ១០.០០០ ក្បាល និងឯកសារព័ត៌មានជាច្រើនទៀតដល់ ៤៥ សាកលវិទ្យាល័យរដ្ឋ និងសាកលវិទ្យាល័យឯកជន នៅក្នុង ១២ ខេត្ត រាប់ទាំង មជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រឹតការ បណ្ឌិតសភានគរបាល និងយោធា វិទ្យាស្ថានពុទ្ធសាសនបណ្ឌិតមួយ និងសាលារៀននានា ដែលផ្តល់វគ្គបណ្តុះបណ្តាលច្បាប់ ពាណិជ្ជកម្ម និងមនុស្សសាស្ត្រ។ ឯកសារសិទ្ធិមនុស្សក៏មានដាក់តាំងផងដែរ នៅតាមក្រសួង-មន្ទីរក្នុងរដ្ឋាភិបាល។ លើសពីនេះទៀត សៀវភៅបោះពុម្ពផ្សាយអំពីសិទ្ធិមនុស្សច្រើនជាង ៣០.០០០ ក្បាល ត្រូវបានធ្វើការចែកចាយទៅតាមក្រសួង-មន្ទីរនានា នៅទូទាំងប្រទេសកម្ពុជា តាមរយៈវគ្គបណ្តុះបណ្តាលទូលំទូលាយ និងសកម្មភាពលើកកំពស់ការយល់ដឹងរបស់ការិយាល័យOHCHR ប័ណ្ណស្ទិចឃើប្រមាណជា ១៦.០០០ សន្លឹក និងប័ណ្ណប៉ុស្ទិចំនួន ៤០ សន្លឹក ត្រូវបានចែកចាយនៅក្នុងពិធីអបអរសាទរទិវាសិទ្ធិមនុស្ស ក្នុងខែធ្នូ ឆ្នាំ២០១១។

៦១. ការិយាល័យOHCHR ក៏បានចូលរួមផងដែរ ជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកស្ទួយសិទ្ធិមនុស្ស។ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីលើកកំពស់ការយល់ដឹងអំពីសិទ្ធិជនជាតិដើមភាគតិច ការិយាល័យ OHCHR បានសម្របសម្រួលផ្នែកមួយនៃកម្មវិធីទូរទស្សន៍ "កម្មវិធីសមធម៌ប្រចាំសប្តាហ៍" របស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) ដែលផ្សាយតាមបណ្តាញទូរទស្សន៍ជាតិ ពាក់ព័ន្ធនឹងបញ្ហាជនជាតិដើមភាគតិច និងនៅក្នុងពិធីអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក។ ការចាក់ផ្សាយតាមវិទ្យុក៏ជាមធ្យោបាយមួយសំខាន់ផងដែរ ក្នុងការបញ្ជូនសារសិទ្ធិមនុស្សនៅក្នុងទិវាសិទ្ធិមនុស្សអន្តរជាតិ។ ដោយសហការជាមួយមូលនិធិសហប្រជាជាតិសំរាប់ប្រជាជន(UNFPA) ការិយាល័យOHCHR បានចាក់បញ្ចាំងខ្សែភាពយន្តខ្លីៗនៅតាមបណ្តាខេត្តនានា អំពីសិទ្ធិមនុស្ស និងសិទ្ធិបន្តពូជ។ នៅទីបំផុត ដោយសហការជាមួយទីភ្នាក់ងារផ្សេងៗរបស់អង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល

ការិយាល័យOHCHR បានរៀបចំព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ រាប់ទាំងយុទ្ធនាការ ១៦ ថ្ងៃ ប្រឆាំងនឹងអំពើហិង្សាលើយេនឌ័រ ទិវាលំនៅឋានពិភពលោក ទិវាសិទ្ធិនារីអន្តរជាតិ ទិវាជនជាតិដើមភាគតិចពិភពលោក ទិវាសេរីភាពសារព័ត៌មានពិភពលោក និងទិវាអន្តរជាតិគាំទ្រជនរងគ្រោះនៃអំពើទារុណកម្ម តាមរយៈការសហការរៀបចំវេទិកាសាធារណៈ ការចាក់បញ្ចាំងខ្សែភាពយន្ត សន្និសិទកាសែត និងការបោះពុម្ពផ្សាយព័ត៌មាន និងឯកសារតស៊ូមតិ រាប់ទាំងអត្ថបទបញ្ចេញមតិ នៅលើទំព័រកាសែតធំៗមួយចំនួនផងដែរ។

៦២. ធ្វើទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងលើកកំពស់ការចូលរួមពីអ្នកសារព័ត៌មាន ក្នុងវិស័យសិទ្ធិមនុស្ស គឺជាផ្នែកស្នូលមួយទៀត នៃការងាររបស់ការិយាល័យOHCHR។ ក្រៅពីការរៀបចំឲ្យមានកិច្ចពិភាក្សាពេលទទួលទានកាហ្វេសំរាប់អ្នកសារព័ត៌មាន និងការឧបត្ថម្ភគាំទ្រដល់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ការិយាល័យOHCHR បានសាកល្បងអនុវត្តកម្មវិធីបណ្តុះបណ្តាលដល់អ្នកវិជ្ជាជីវៈសារព័ត៌មានក្នុងស្រុកចំនួន ២៤ នាក់ ស្តីពីបទដ្ឋានសិទ្ធិមនុស្សក្នុងវិជ្ជាជីវៈសារព័ត៌មាន ក្នុងខែតុលា ឆ្នាំ២០១១។ ក្នុងឆ្នាំ២០១១/២០១២ ជំនួយហិរញ្ញប្បទានរបស់កម្មវិធី បានផ្តោតលើសិទ្ធិកុមារ។ ហិរញ្ញប្បទានមួយ ត្រូវបានផ្តល់ឲ្យអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ឈ្មោះ អង្គការមិត្តសំលាញ់ ("Friends") ដើម្បីជួយដល់មនុស្សវ័យក្មេង និងកុមារអនាថារស់នៅតាមចិញ្ចើមថ្នល់ចំនួន១៨០ នាក់ ឲ្យមានការយល់ដឹងថែមទៀត អំពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន តាមរយៈការពិភាក្សាគ្នានៅក្នុងថ្នាក់រៀន អំពីខ្លឹមសារសំខាន់ក្នុងស្នាដៃសិល្បៈ និងការសំដែងជាសាធារណៈ។ ការិយាល័យOHCHR បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ ដល់អង្គការ Pour un Sourire d'Enfant (PSE) ដើម្បីផលិតជាខ្សែវីដេអូ ក្នុងគោលដៅលើកកំពស់ការយល់ដឹងអំពីការរំលោភផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ និងទាសភាព ដែលកន្លងមក បានចាក់បញ្ចាំងឲ្យសិស្សនិស្សិតជាង ៣.២០០ នាក់ ទស្សនា ដែលពួកគេមកពីគ្រឹះស្ថានអប់រំ និងសាលារៀនរដ្ឋនានា ដែលសមាគមនេះបានឧបត្ថម្ភគាំទ្រ។

**VII. ការធ្វើរបាយការណ៍ និងតាមមើលការអនុវត្ត**

៦៣. ប្រទេសកម្ពុជាបានបន្តបង្ហាញពីប្រវត្តិការណ៍ដ៏រឹងមាំរបស់ខ្លួន អំពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញានានា។ រដ្ឋាភិបាលបានសន្យាផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅត្រឹមបំណាច់ ឆ្នាំ២០១២។ ការិយាល័យ OHCHR បានបន្តជួយឧបត្ថម្ភដល់កម្ពុជា ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការធ្វើរបាយការណ៍តាមកាលកំណត់ ក្រោមសន្ធិសញ្ញាទាំងឡាយ ដែលកម្ពុជាគឺជាភាគី។ របាយការណ៍ដែលនៅសល់ចុងក្រោយគេ របស់កម្ពុជា ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR) ត្រូវបានរំពឹងថានឹងបញ្ជូននៅពេលដ៏ខ្លីខាងមុខនេះ ក្នុងឆ្នាំ២០១២។ ទោះបីជារដ្ឋាភិបាល បានចាត់វិធានការអនុវត្តរបាយការណ៍របស់អនុគណៈកម្មាធិការប្រឆាំងទារុណកម្ម ដែលបានធ្វើនៅក្នុងពេលនៃដំណើរទស្សនកិច្ចរបស់ខ្លួនមកកាន់កម្ពុជាក្នុងឆ្នាំ២០០៩ ហើយក្តី ក៏របាយការណ៍នេះ នៅតែរក្សាការសំងាត់ដដែល។ ការិយាល័យOHCHR សូមស្នើដល់រដ្ឋាភិបាលឲ្យធ្វើការផ្សព្វផ្សាយរបាយការណ៍នោះជាសាធារណៈ។

៦៤. ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ បានឃើញការវិវត្តជាដុំកំភួននៃការអនុវត្តរបស់រដ្ឋាភិបាលនូវអនុសា-សន៍ នៃការពិនិត្យរបាយការណ៍សកលតាមកាលកំណត់ (អនុសាសន៍ UPR) ទាំង ៩១ ដែលកម្ពុជាបានទទួលយកក្នុងខែធ្នូ ឆ្នាំ២០០៩។ ក្នុងខែកក្កដា ឆ្នាំ២០១១ ការិយាល័យOHCHR ដោយសហការជាមួយចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង ស៊ុយអែត និងសហភាពអឺរ៉ុប បានគាំទ្រដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(CHRC) ក្នុងការកោះប្រជុំមួយរវាងសង្គមស៊ីវិល និងក្រសួងនានា ដើម្បីរៀបចំបង្កើតក្របខ័ណ្ឌជាមូលដ្ឋាន និងផែនការសកម្មភាព ដើម្បីអនុវត្តអនុសាសន៍ខាងលើ។ នេះជាកិច្ចប្រជុំលើកដំបូងមួយ ដែលមានការចូលរួមពីពហុវិស័យរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល

ពិភាក្សាលើវិស័យសិទ្ធិមនុស្សសំរាប់រយៈពេលប៉ុន្មានឆ្នាំទៅមុខ។ អ្នកចូលរួមក្នុងកិច្ចប្រជុំនេះ បានស្តាប់សន្ទរកថារបស់តំណាងមួយរូបនៃគណៈកម្មការជាតិសិទ្ធិមនុស្សម៉ាឡេស៊ី(Suhakam) អំពីបទពិសោធរបស់ប្រទេសនេះ ក្នុងការអនុវត្តអនុសាសន៍នៃការពិនិត្យរបាយការណ៍សកលតាមកាលកំណត់។ ការិយាល័យOHCHR បានធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(CHRC) ក្នុងការរៀបចំផែនការសកម្មភាពសំរាប់ក្រសួងនីមួយៗ ដោយធ្វើការបរិយាយអំពីវិធីសាស្រ្តផ្សេងៗដែលរដ្ឋាភិបាលអាចអនុវត្តអនុសាសន៍ទាំងនេះ នៅមុនពេលដែលកម្ពុជានឹងត្រូវបានពិចារណាសំរាប់ការពិនិត្យរបាយការណ៍នៅជុំទីពីរទៀត។ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យOHCHR បានឧបត្ថម្ភគាំទ្រដល់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នៅក្នុងពេលនៃដំណើរបេសកកម្មចំនួនពីរលើករបស់លោក មកកាន់ប្រទេសកម្ពុជា។[5]

## VIII. ការងារបុគ្គលិក

៦៥. ការិយាល័យOHCHR មានទីស្នាក់ការកណ្តាល នៅរាជធានីភ្នំពេញ និងមានការិយាល័យថ្នាក់តំបន់មួយនៅខេត្តបាត់ដំបង ដោយមានតំណែងបុគ្គលិកអន្តរជាតិចំនួន ៨ និងអ្នកស្ម័គ្រចិត្តអន្តរជាតិអង្គការសហប្រជាជាតិចំនួនមួយ បុគ្គលិកជាតិចំនួន ៣២ និងបុគ្គលិកសេវាកិច្ចសន្យាចំនួនបី។ បុគ្គលិកបានកើនឡើងបួនមុខតំណែង នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។

-------------------------

[5] សូមអាន A/HRC/21/63 and Add.1.